- បានឃើញអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៦៥អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**មាត្រា១._**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន២៤៦ ០០០ ០០០រៀល (ពីររយសែសិបប្រាំមួយលានរៀលគត់) ពីជំពូក០៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក៦០ (ការទិញ) ជូនក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**មាត្រា២._**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទិញរថយន្តថ្មីចំនួន០៣គ្រឿង។

**មាត្រា៣._**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៧៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១០២ អនក្រ.បក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០២ ស្តីពីការកំណត់ការចំណាយដោយឡែក សម្រាប់អនុវត្តកម្មវិធីសកម្មភាពជាអាទិភាព នៅក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ ស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុងនិងក្រៅប្រទេស
- បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងកំណត់អាហារូបករណ៍និងប្រាក់ឧបត្ថម្ភប្រចាំខែចំពោះអ្នកសិក្សា ដើម្បីទំនុកបម្រុងការសិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅ៖

- ផ្តល់អាហារូបករណ៍ដល់អ្នកសិក្សាកម្រិតបឋមសិក្សាឯកទេស កម្រិតមធ្យមសិក្សាឯកទេស កម្រិតបរិញ្ញាបត្រ និងកម្រិតក្រោយបរិញ្ញាបត្រ
- ផ្តល់ប្រាក់ឧបត្ថម្ភដល់មន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ច អនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះអ្នកសិក្សាដែលទទួលការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងមន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស ស្របតាមច្បាប់ស្តីពីការអប់រំ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើនៅក្នុងអនុក្រឹត្យនេះ មានភ្ជាប់ជាឧបសម្ព័ន្ធ។

## ជំពូកទី២

## កម្រិតនិងលក្ខខណ្ឌនៃការផ្តល់អាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក

**មាត្រា៥ .-**

អាហារូបករណ៍ប្រចាំខែរបស់សិស្សនិងនិស្សិត ដែលបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេសសាធារណៈ ត្រូវកំណត់តាមកម្រិតដូចខាងក្រោម៖

- ក្រោយបរិញ្ញាបត្រ : ៨០ ០០០រៀល

- បរិញ្ញាបត្រ : ៤៥ ០០០រៀល
- មធ្យមសិក្សាឯកទេស : ៤០ ០០០រៀល
- បឋមសិក្សាឯកទេស : ៣០ ០០០រៀល។

**មាត្រា៦ .-**

ចំនួនសិស្សនិងនិស្សិតដែលទទួលអាហារូបករណ៍ ត្រូវកំណត់ដូចតទៅ៖

- កម្រិតក្រោយបរិញ្ញាបត្រ : ២៥ភាគរយ
- កម្រិតបរិញ្ញាបត្រ : ១០ភាគរយ
- កម្រិតមធ្យមសិក្សាឯកទេស : ៣០ភាគរយ
- កម្រិតបឋមសិក្សាឯកទេស : ៣៥ភាគរយ។

ចំពោះសិស្សនិងនិស្សិត ដែលទទួលការបណ្តុះបណ្តាលមុខជំនាញដែលរាជរដ្ឋាភិបាលកំណត់ថាជាមុខជំនាញអាទិភាព ឬមុខជំនាញចាំបាច់សម្រាប់សង្គម ដូចជាកីឡានិងគ្រូបង្រៀនគ្រប់កម្រិត ត្រូវទទួលអាហារូបករណ៍មួយរយភាគរយ។

**មាត្រា៧ .-**

ការផ្តល់អាហារូបករណ៍ប្រចាំខែ ត្រូវអនុវត្តតែក្នុងរយៈពេលកំពុងសិក្សា។ ពេលឈប់សម្រាកក្នុងឱកាសមហាវិស្សមកាលនិងពេលព្យួរការសិក្សា សិស្សនិងនិស្សិតមិនត្រូវបានទទួលប្រាក់អាហារូបករណ៍ឡើយ។

ក្នុងករណីសិស្ស និស្សិតដែលរៀនត្រួតថ្នាក់ រដ្ឋនឹងផ្តាច់អាហារូបករណ៍វិញ លើកលែងតែគរុសិស្សនិងគរុនិស្សិត។

**មាត្រា៨ .-**

ការផ្តល់អាហារូបករណ៍ ត្រូវអនុវត្តតាមគោលការណ៍អាទិភាព ដូចខាងក្រោម៖

១- សិស្ស និស្សិត គោរពវិន័យបានល្អនិងរៀនពូកែ។

២- កូនកំព្រាឪពុកនិង/ឬម្តាយ មានជីវភាពក្រីក្រ។

៣- កូនជនជាតិដើមភាគតិច។

៤- សិស្ស និស្សិតដែលមកពីគ្រួសារក្រីក្រ។

ក្នុងអាទិភាពទាំង៤ខាងលើ នារីភេទត្រូវបានយកចិត្តទុកដាក់មុនគេ។

**មាត្រា៩ .-**

ការកំណត់ឈ្មោះសិស្សនិងនិស្សិតដែលត្រូវបានទទួលអាហារូបករណ៍ និងការពិនិត្យវាយតម្លៃផ្តល់អាទិភាពដូចក្នុងមាត្រា៦និងមាត្រា៨នៃអនុក្រឹត្យនេះ ត្រូវរៀបចំមួយឆ្នាំម្តង ដោយគណៈកម្មការជ្រើសរើសអាហារូបករណ៍របស់គ្រឹះស្ថានសិក្សា។

នីតិវិធីនិងការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការជ្រើសរើសអាហារូបករណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធនីមួយៗ។

**មាត្រា១០ .-**

គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ដែលបានប្រែក្លាយជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវប្រើថវិការបស់ខ្លួនក្នុងការរ៉ាប់រងបើកប្រាក់អាហារូបករណ៍ប្រចាំខែជូនដល់សិស្ស និស្សិតអាហារូបករណ៍ដែលកំពុងសិក្សា ដូចមានកំណត់នៅមាត្រា៥ មាត្រា៦ មាត្រា៧ និងមាត្រា៨នៃអនុក្រឹត្យនេះ។

**មាត្រា១១ .-**

ចំពោះមន្ត្រីរាជការគ្រប់ប្រភេទដែលក្រសួង ស្ថាប័នមានសមត្ថកិច្ចអនុញ្ញាតឱ្យទៅចូលរួមសិក្ខាសាលា ធ្វើវិក្រឹតការ សុក្រឹតការ ឬវគ្គបំប៉នមុខជំនាញផ្សេងៗនៅក្នុងប្រទេស រយៈពេលពី០១(មួយ)ថ្ងៃដល់១០(ដប់)ថ្ងៃ ត្រូវទទួលប្រាក់ស្នាក់នៅនិងប្រាក់បេសកកម្មតាមច្បាប់រដ្ឋ។ អ្នកចូលរួមដែលមានទីលំនៅនៅជិតជាង១០គីឡូម៉ែត្រ ត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន១០ ០០០(មួយម៉ឺន)រៀល ក្នុងមួយថ្ងៃ។

ចំណែកឯវគ្គសិក្សាដែលមានរយៈពេលចាប់ពី១១(ដប់មួយ)ថ្ងៃរហូតដល់តិចជាង១២(ដប់ពីរ)ខែ ត្រូវទទួលប្រាក់ឧបត្ថម្ភអន្តេវាសិកចំនួន៨ ០០០(ប្រាំបីពាន់)រៀលក្នុងមួយថ្ងៃ ដោយមិនអនុញ្ញាតឱ្យទទួលរបបបេសកកម្មតាមការកំណត់របស់រដ្ឋបន្ថែមទៀតឡើយ។ អ្នកចូលរួមដែលមានទីលំនៅនៅជិត អាចមកស្នាក់នៅផ្ទះរបស់ខ្លួនបានក្នុងរាជធានី ខេត្ត ត្រូវទទួលប្រាក់ឧបត្ថម្ភចំនួន៥ ០០០(ប្រាំពាន់)រៀល ក្នុងមួយថ្ងៃ ហើយផ្តល់ជូនសម្រាប់ថ្ងៃបំពេញការងារ។

**មាត្រា១២ .-**

សិស្សជនជាតិដើមភាគតិចនិងសិស្សមានជីវភាពក្រីក្រ ដែលមកសិក្សានៅក្នុងអន្តេវាសិកដ្ឋាននៃអនុវិទ្យាល័យ វិទ្យាល័យ ឬទីប្រជុំជនស្រុក ឃុំដែលមានអន្តេវាសិកដ្ឋាន ត្រូវបានទទួលប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃម្នាក់ៗចំនួន៤ ២០០(បួនពាន់ពីររយ)រៀល និងរបបឧបត្ថម្ភសម្រាប់សម្ភារៈដំណេកនិងសម្ភារៈសិក្សាប្រចាំឆ្នាំ ក្នុងម្នាក់ៗចំនួន១០០ ០០០(មួយសែន)រៀល។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា១៣ .-**

អាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ ត្រូវអនុវត្តចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៤ តទៅ។

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំលិខិតបទដ្ឋានគតិយុត្តដើម្បីអនុវត្តអនុក្រឹត្យនេះ។

**មាត្រា១៤ .-**

អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៩៧ ស្ដីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន

សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## នៃអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ២០១៤

## ស្តីពីអាហារូបករណ៍និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិត សិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

**កម្រិតក្រោយបរិញ្ញាបត្រ** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្របរិញ្ញាបត្រឬសញ្ញាបត្រដែលមានតម្លៃស្មើធ្វើជាមូលដ្ឋាន សម្រាប់ទទួលការបណ្តុះបណ្តាលបន្ត និងមានរយៈពេលបណ្តុះបណ្តាល ចាប់ពី១ឆ្នាំឡើងទៅ។

**កម្រិតបឋមសិក្សាឯកទេស** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំណេះទូទៅឬបំពេញវិជ្ជា ឬសញ្ញាបត្រ ដែលមានតម្លៃស្មើធ្វើជាមូលដ្ឋានសម្រាប់ទទួលការបណ្តុះបណ្តាល និងមានរយៈពេលបណ្តុះបណ្តាលបន្តចាប់ពី៦ខែទៅ៣ឆ្នាំ ដោយផ្អែក ទៅតាមមុខជំនាញ។

**កម្រិតមធ្យមសិក្សាឯកទេស** សំដៅដល់កម្រិតបណ្តុះបណ្តាលដែលអ្នកសិក្សាត្រូវបំពេញលក្ខខណ្ឌ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិចំណេះទូទៅ ឬបំពេញវិជ្ជា ឬសញ្ញាបត្រ ដែលមានតម្លៃស្មើធ្វើជាមូលដ្ឋានសម្រាប់ទទួលការបណ្តុះបណ្តាល និងមានរយៈពេលបណ្តុះបណ្តាលចាប់ពី២ឆ្នាំទៅ៤ឆ្នាំកន្លះ ដោយផ្អែក ទៅតាមមុខជំនាញ។

**របបឧបត្ថម្ភជីវភាព** សំដៅដល់ប្រាក់ឧបត្ថម្ភជីវភាពប្រចាំថ្ងៃ សម្ភារៈដំណេក និងសម្ភារៈ សិក្សាប្រចាំឆ្នាំ សម្រាប់ជួយទំនុកបម្រុងអ្នកសិក្សាដែលស្នាក់នៅអន្តេ-វាសិកដ្ឋាន។

**វគ្គបំប៉ន** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីផ្តល់នូវសំណុំចំណេះដឹង ជំនាញ និងតម្លៃ បំពេញបន្ថែមឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទី និងភារកិច្ចដែលបានកំណត់។

**វគ្គវិក្រឹតការ** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីអភិវឌ្ឍវិជ្ជាជីវៈជាប់ជាប្រចាំតាម កាលកំណត់ឬការចាំបាច់របស់ក្រសួង ស្ថាប័ន។

**វគ្គសុក្រឹតការ** សំដៅដល់វគ្គបណ្តុះបណ្តាលបន្តដើម្បីលើកកម្ពស់សមត្ថភាពឱ្យបាន ល្អប្រសើរជាងមុនសក្តិសមនឹងតួនាទីនិងភារកិច្ចដែលកំពុងបំពេញ ការងារ។

**សិក្ខាសាលា** សំដៅដល់ការប្រជុំដើម្បីផ្សព្វផ្សាយ ពិគ្រោះយោបល់ ណែនាំ ផ្តល់ព័ត៌មាន បទពិសោធ...ដល់សិក្ខាកាមដែលបានកំណត់តាមមុខវិជ្ជា។

**អាហារូបករណ៍** សំដៅដល់ប្រាក់ដែលផ្តល់ឱ្យដល់អ្នកសិក្សា ដើម្បីទំនុកបម្រុងការ សិក្សាក្នុងរយៈពេលកំពុងរៀនសូត្រ។

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៣៩៩ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពីការបញ្ចប់មុខតំណែងមន្ត្រីរាជការ និងតែងតាំងមន្ត្រីរាជការ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ១៩៩៦ ត្រាស់បង្គាប់បង្កើតក្រសួងព្រះបរមរាជវាំង
- អនុក្រឹត្យលេខ ៧២ អនក្រ.តត ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល
- អនុក្រឹត្យលេខ ៦៥២ អនក្រ.តត ចុះថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០០៩ របស់រាជរដ្ឋាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងព្រះបរមរាជវាំង ។

### ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបញ្ចប់មុខតំណែងមន្ត្រីរាជការ នៃក្រសួងព្រះបរមរាជវាំង **០២ រូប** :

១-លោក **សូ ស៊ីនួន** ឧត្ដមមន្ត្រីថ្នាក់លេខ ៣ ពីប្រធាននាយកដ្ឋាន ដឹកជញ្ជូន

២-លោក **គឹម សៀ** ឧត្ដមមន្ត្រីថ្នាក់លេខ ១ ពីប្រធាននាយកដ្ឋាន ផែនការ-គណនេយ្យ

**មាត្រា ២ :** ត្រូវបានតែងតាំងមន្ត្រីរាជការ នៃក្រសួងព្រះបរមរាជវាំង **០៣ រូប** :

១-លោក **ម៉ែន វុទ្ធី** ឧត្ដមមន្ត្រីថ្នាក់លេខ ៣ ជាប្រធាននាយកដ្ឋាន ផែនការ-គណនេយ្យ

២-លោក **ឡាច សុភាព** ឧត្ដមមន្ត្រីថ្នាក់លេខ ៥ ជាប្រធាននាយកដ្ឋាន ពិធីការ

៣-លោក **ពិន សារ៉ាត** វរមន្ត្រីថ្នាក់លេខ ៨ ជាប្រធាននាយកដ្ឋាន ដឹកជញ្ជូន

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន :**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋាន រដ្ឋសភា*
- *អគ្គលេខាធិការដ្ឋាន រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ  សាសនា  ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤០០ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

**សម្រេច**

**មាត្រា ១ :** ត្រូវបានតែងតាំង លោក **ពាន ចំរើន** ជាប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក និងគ្រឿងឥស្សរិយយស នៃអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យ សម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤០១ អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១.—**

ត្រូវបានបំពាក់ **មេដាយមាសការងារ** ផ្ដល់ជូន មន្ត្រីរាជការ ចំនួន ១០រូប ដែលបានលះបង់កំលាំងកាយចិត្ត និងបរិច្ចាគធនធានផ្ទាល់ខ្លួនចូលរួមចំណែកជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋានលើគ្រប់វិស័យ ស្ថិតនៅក្នុងឃុំតាប៉ុន ស្រុកសង្កែ ខេត្តបាត់ដំបង អោយមានការរីកចំរើនគួរជាទីមោទនៈ ដែលមានរាយនាមដូចខាងក្រោម :

| | |
|---|---|
| ១-លោក **អ៊ុក ម៉េងពី** | ៦-លោក **ថៃ វីរិទ្ធ** |
| ២-លោក **ហាស់ សីហា** | ៧-លោកស្រី **ទន់ សុខឃីម** |
| ៣-លោក **ប្រាក់ យាង** | ៨-លោក **យ៉ែម រាជនី** |
| ៤-លោក **សូ រតនា** | ៩-លោក **ផល បញ្ញា** |
| ៥-លោក **សៀក សុខសម្បត្តិ** | ១០-លោក **ភោគ វឌ្ឍនា** |

**មាត្រា ២.—**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ  សាសនា  ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤០២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១..** បំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនអង្គភាព JHP ដែលបានផ្តល់ថវិកាជួយកសាងអគារសិក្សា០១ខ្នង មាន០៥បន្ទប់ ព្រមទាំងបំពាក់គ្រឿងសង្ហារិមគ្រប់គ្រាន់ ជូនសាលាបឋមសិក្សាទួលជ្រៃ ស្ថិតនៅភូមិស្វាយចេក ឃុំឫស្សីស្រុក ស្រុកពាមជរ ខេត្តព្រៃវែង ។

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀង១ខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤០៣ [illegible]

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន

**សម្រេច**

**មាត្រា១.**- បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនសប្បុរសជនបរទេស ចំនួន០២រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ខេត្តប៉ៃលិន កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-Ms. | Khuon saruon | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.០០០ ដុល្លារ |
| ២-Mrs. | Douglas seda | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.០០០ ដុល្លារ |

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលគណៈអភិបាលខេត្តប៉ៃលិន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤០៤ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់អភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន

## សម្រេច

**មាត្រា១.**- បំពាក់ មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ ជូនសប្បុរសជនបរទេស ចំនួន១៣រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាង និងអភិវឌ្ឍន៍ខេត្តប៉ៃលិន កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-Mr. | Father goto fumio | | សប្បុរសជនជប៉ុន | ថវិកាចំនួន ១០.១៥០ ដុល្លារ |
| ២-Mr. | Amatax | Group | សប្បុរសជនជប៉ុន | ថវិកាចំនួន ១០.១៣៥ ដុល្លារ |
| ៣-Mr. | Yuth | Chhieng | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៤-Ms. | Kuon | Kunnaka | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៥-Mr. | Tan | Kevin | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៦-Ms. | Hay | Sopharany | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៧-Mr. | Lim | Richardsour | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៨-Mrs. | Lim | ann | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ៩-Mr. | Neale | anthony | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ១០-Mrs. | Nhieu | helen | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |
| ១១-Dr. | Macnab | Francis | សប្បុរសជនអូស្ត្រាលី | ថវិកាចំនួន ១០.000 ដុល្លារ |

**ខ-មេដាយប្រាក់ស្ថាបនាជាតិ**

| | | | | |
|---|---|---|---|---|
| ១-Ms. | Kuihiro | kanako | សប្បុរសជនជប៉ុន | ថវិកាចំនួន ៦.០២០ ដុល្លារ |
| ២-Mr. | Yoshida | naoya | សប្បុរសជនជប៉ុន | ថវិកាចំនួន ៥.៨១៥ ដុល្លារ |

**មាត្រា២.**- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អភិបាលគណៈអភិបាលខេត្តប៉ៃលិន និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១.**. បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជូននាយចំណង់ **អ៊ឹម ទិបុល** អត្តលេខ ១៣១៣៨៥ ជំនួយការការិយាល័យទី១កងពលតូចលេខ៥៣ ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិនិងបានចូលរួមជួយកសាង និងអភិវឌ្ឍន៍មូលដ្ឋាន នៅស្រុកកំរៀង ស្រុកភ្នំព្រឹក ក្នុងខេត្តបាត់ដំបង ។

**មាត្រា២.**.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ [illegible] ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:..៤០៧..អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១..** បំពាក់ **មេដាយសិរីវឌ្ឍនស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន០៦រូប ដែលមានស្នាដៃល្អក្នុងការចូលរួមជួយកសាងសមិទ្ធផលនានា នៅស្រុកកំរៀង និងស្រុកភ្នំព្រឹក ក្នុងខេត្តបាត់ដំបង កន្លងមក ដូចមានរាយនាមខាងក្រោម ៖

| | | | | | |
|---|---|---|---|---|---|
| ១-វរសេនីយ៍ទោ | សុខ | តុខ | អត្តលេខ | ០២២០៨៤ | នាយការិយាល័យទី១ កងពលតូចលេខ៥៣ ទឹកប្រាក់៤.៤០០.០០០រៀល |
| ២-វរសេនីយ៍ត្រី | ឡូន | សារឿន | អត្តលេខ | ០០៣៧២១ | មេបញ្ជាការរង វរសេនាតូចលេខ៥៣១ កងពលតូចលេខ៥៣ ទឹកប្រាក់៤.៤០០.០០០រៀល |
| ៣-អនុសេនីយ៍ទោ | ព្រហ្ម | ម៉ៅ | អត្តលេខ | ០៨៧៦១៥ | មេបញ្ជាការរង អនុសេនាធំទី២ វរសនាតូច៥៣៣ កងពលតូចលេខ៥៣ ទឹកប្រាក់៧.៥០០.០០០រៀល |
| ៤-នាយចំណង់ | សាយ | មិត្តជ័យ | អត្តលេខ | ០៧៥៣៧៥ | បុគ្គលិក បំរើការការិយាល័យទី១ កងពលតូចលេខ៥៣ ទឹកប្រាក់៤.៤០០.០០០រៀល |
| ៥-ព្រិន្ទបាលទោ | ហេង | ចំណាប់ | អត្តលេខ | ១៣១៤៩៣ | យុទ្ធជន វរសេនាតូចលេខ៥៣៣ កងពលតូចលេខ៥៣ ទឹកប្រាក់៤.៤០០.០០០រៀល |
| ៦-លោក | ឆា | ហ៊ួន | | | អាជីវករក្រុងប៉ោយប៉ែត ទឹកប្រាក់១០.៤០០.០០០រៀល |

**មាត្រា២..** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និងមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤០៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយការងារ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់មេបញ្ជាការកងទ័ពជើងគោក

## សម្រេច

**មាត្រា១.** បំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអង្គភាព ចំនួន០១ និងនាយទាហាន ចំនួន៩៩រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមាសការងារ**

**១ -អង្គភាព គយរង្កាករច្រករំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង**

| | | | | | | |
|---|---|---|---|---|---|---|
| ២ | -វរសេនីយ៍ទោ | **ទូច** | **សុវណ្ណារ៉ា** | អត្តលេខ | ០៣៧៣៤៧ | នាយរងផ្នែកឥស្សរិយយស-សរសើរ ការិយាល័យទី១ |
| ៣ | -វរសេនីយ៍ត្រី | **ញឹម** | **សុខា** | អត្តលេខ | ០១០៧១៩ | ជំនួយការ មេបញ្ជាការ កងពលតូចលេខ៥៣ |
| ៤ | -អនុសេនីយ៍ឯក | **ស៊ុក** | **សុខុម** | អត្តលេខ | ០៥៤២៦៩ | បុគ្គលិក រដ្ឋបាល វរសេនាតូចលេខ៥៣៤ កងពលតូចលេខ៥៣ |
| ៥ | -អនុសេនីយ៍ឯក | **សែម** | **សាន** | អត្តលេខ | ០២១៤៤៤ | មេបញ្ជាការរង អនុសេនាធំ៣ វរសេនាតូច កងពលតូចលេខ៥៣ |
| ៦ | -អនុសេនីយ៍ទោ | **រី** | **ឡាយ** | អត្តលេខ | ០៣២៦៨៥ | មេបញ្ជាការរងអនុសេនាតូច៣អនុសេនាធំ៣ វរសេនាតូចលេខ៥៣៤កងពលតូចលេខ៥៣ |
| ៧ | -អនុសេនីយ៍ទោ | **កែន** | **ពល** | អត្តលេខ | ០៣២៧២១ | មេបញ្ជាការរង អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ៨ | -អនុសេនីយ៍ទោ | **ស្នួន** | **កំសាន្ត** | អត្តលេខ | ០៧៣៧៨៤ | មេបញ្ជាការរង អនុសេនាធំ កាំភ្លើងធំ កងពលតូចលេខ៥៣ |
| ៩ | -អនុសេនីយ៍ទោ | **ដួន** | **ចាន់ថន** | អត្តលេខ | ០៧៣៤៧៩ | ជំនួយការ សុខាភិបាល កងពលតូចលេខ៥៣ |
| ១០ | -អនុសេនីយ៍ទោ | **មៀន** | **សុវណ្ណ** | អត្តលេខ | ០៤២១៧០ | ជំនួយការ ភស្តុភារបច្ចេកទេស ការិយាល័យទី៤ កងពលតូចលេខ៥៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ១១ | -អនុសេនីយ៍ទោ | កែវ | ឈុនលី | អត្តលេខ | ០៤២១៦៩ | ជំនួយការ អាវុធគ្រាប់ ការិយាល័យទី៤ កងពលតូចលេខ៥៣ |
| ១២ | -អនុសេនីយ៍ទោ | ឡើន | ពិសិដ្ឋ | អត្តលេខ | ០៥៨៥៥៨ | ជំនួយការ ទ័ណ្ឌកម្ម សរសើរ ការិយាល័យទី១ កងពលតូចលេខ៥៣ |
| ១៣ | -អនុសេនីយ៍ទោ | សុខ | សារឿន | អត្តលេខ | ០២១៣៧៤ | មេបញ្ជាការរង អនុសេនាធំគាំទ្រ កងពលតូចលេខ៥៣ |
| ១៤ | -អនុសេនីយ៍ទោ | ខាត់ | សីលា | អត្តលេខ | ០៥៣៩៨៣ | មេបញ្ជាការ អនុសេនាតូចឃកាហ្សិត អនុសេនាធំគាំទ្រ កងពលតូចលេខ៥៣ |
| ១៥ | -អនុសេនីយ៍ត្រី | ស្ទូន | សិរី | អត្តលេខ | ០៥៤០៩៥ | បុគ្គលិក ភស្តុភា វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ១៦ | -អនុសេនីយ៍ត្រី | សោ | តឿម | អត្តលេខ | ០៧៥៤២៦ | មេបញ្ជាការ អនុសេនាតូច១ វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ១៧ | -អនុសេនីយ៍ត្រី | ហៃ | តារាក្យ | អត្តលេខ | ០៣២៧៤៦ | មេបញ្ជាការ អនុសេនាតូច វរសេនាតូចលេខ៥៣ កងពលតូចលេខ៥៣ |
| ១៨ | -អនុសេនីយ៍ត្រី | អ៊ុន | តា | អត្តលេខ | ០៣២៧១៥ | មេបញ្ជាការអនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ១៩ | -អនុសេនីយ៍ត្រី | សេន | ភ័ណ្ឌា | អត្តលេខ | ០៣២៦៩៥ | មេបញ្ជាការ អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ២០ | -អនុសេនីយ៍ត្រី | ម៉ាន់ | រី | អត្តលេខ | ០៣២៧០៦ | មេបញ្ជាការ អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ២១ | -អនុសេនីយ៍ត្រី | ចាន់ | សុផល | អត្តលេខ | ០៣២៧៥៧ | មេបញ្ជាការ អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ២២ | -អនុសេនីយ៍ត្រី | អ៊ុន | ពៅទ្រ | អត្តលេខ | ០៤៤០១៤ | មេបញ្ជាការ អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ២៣ | -អនុសេនីយ៍ត្រី | អ៊ួច | ចណ្ណារ: | អត្តលេខ | ០៣០៣៩១ | មេបញ្ជាការរង អនុសេនាតូច១ អនុសេនាធំការពារអាកាស កងពលតូចលេខ៥៣ |
| ២៤ | -អនុសេនីយ៍ត្រី | គឹក | ចិល | អត្តលេខ | ០៥៤១៥៨ | ជំនួយការ គោលនយោបាយ ការិយាល័យទី៥ កងពលតូចលេខ៥៣ |
| ២៥ | -អនុសេនីយ៍ត្រី | អឿន | ម៉េងជាង | អត្តលេខ | ០៩០៧៨១ | ជំនួយការ ព័ត៌មានសិល្ប: ការិយាល័យទី៥ កងពលតូចលេខ៥៣ |
| ២៦ | -អនុសេនីយ៍ត្រី | ឈុប | សែម | អត្តលេខ | ០៣២៨១៣ | មេបញ្ជាការ អនុសេនាតូច ការពារ កងពលតូចលេខ៥៣ |
| ២៧ | -អនុសេនីយ៍ត្រី | ប៉ាន់ | ធិន | អត្តលេខ | ០៥៤២២២ | មេបញ្ជាការរង អនុសេនាធំ ស៊ើបការណ៍ កងពលតូចលេខ៥៣ |
| ២៨ | -នាយចំណង់ | វ៉ែម | តឿយ | អត្តលេខ | ០៤៤៣៨៩ | មេបញ្ជាការរង អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ២៩ | -នាយចំណង់ | កែវ | ពិសី | អត្តលេខ | ០៤៣៩៩០ | មេបញ្ជាការរង អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ៣០ | -នាយចំណង់ | ផាន់ | សុភ័ក្រ | អត្តលេខ | ០៥៤១០៩ | បុគ្គលិក ចលនូបត្ថម វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ៣១ | -នាយចំណង់ | វ៉ែន | ឌីន | អត្តលេខ | ០៥៤០៥៨ | នាយពួក វរសេនាតូចលេខ៥៣៤ កងពលតូចលេខ៥៣ |
| ៣២ | -នាយចំណង់ | ហាទ្យ | ផល្លី | អត្តលេខ | ០៥៤១៥៦ | នាយពួក វរសេនាតូចលេខ៥៣៤ កងពលតូចលេខ៥៣ |
| ៣៣ | -នាយចំណង់ | ម៉ន | នឹម | អត្តលេខ | ០៥៤២៨១ | មេបញ្ជាការរង អនុសេនាតូច វរសេនាតូច លេខ៥៣៤ កងពលតូចលេខ៥៣ |
| ៣៤ | -នាយចំណង់ | ស៊ិន | អ៊ូ | អត្តលេខ | ១០៨០៧១ | មេបញ្ជាការរង អនុសេនាតូច១ អនុសេនាធំ ការពារអាកាស កងពលតូចលេខ៥៣ |
| ៣៥ | -នាយចំណង់ | សាន | ឆាយ | អត្តលេខ | ០៧៥២៥៣ | គ្រូពេទ្យគិលានដ្ឋាន កងពលតូចលេខ៥៣ |
| ៣៦ | -ព្រិន្ទបាលឯក | ច័ន្ទ | ម៉ារីរដ្ឋា | អត្តលេខ | ០៥៤២៤៥ | បុគ្គលិក ពេទ្យបឋមគិលានុដ្ឋាន កងពលតូចលេខ៥៣ |
| ៣៧ | -ព្រិន្ទបាលទោ | ហ៊ឹម | សុភ័ត្រា | អត្តលេខ | ១៣១៣៩១ | ពេទ្យបឋម គិលានដ្ឋាន កងពលតូចលេខ៥៣ |
| ៣៨ | -ព្រិន្ទបាលទោ | ចាន់ | សាវ៉ុន | អត្តលេខ | ០៨២៣០២ | បុគ្គលិក បំរើការ គិលានដ្ឋាន លេខ៥៣៤ កងពលតូចលេខ៥៣ |

៣៩ -លោក **គឹម ប្រុស** ប្រធានកាំកុងត្រូល ច្រកអូរវំដួល ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

៤០ -លោក **គឿន លុត** អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

៤១ -លោក **ហាម សំខាន់** ប្រធានច្រកទំនាក់ទំនងសំពៅលូន ខេត្តបាត់ដំបង

៤២ -លោក **អ៊ុន សិរីវឌ្ឍនៈ** នាយទាហាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៤៣ -លោក **ឃឹម ម៉ុនណារ៉ុម** នាយទាហាន បញ្ជាការដ្ឋានវិស្វកម្ម កងទ័ពជើងគោក

៤៤ -លោក **វឌ្ឍនៈ ការុណា** មន្ត្រី

៤៥ -លោក **ខៀវ ភូណែល** មន្ត្រី

៤៦ -លោក **ស្រ៊ឹម ម៉ាន់ដែន** មន្ត្រី

## ខ-មេដាយប្រាក់ការងារ

១ -អនុសេនីយ៍ត្រី **យិន ចាន់ធី** អត្តលេខ ១០៨០១៣ មេ.ការរង អនុ.តូច៣ អនុ.ធំការពារអាកាស កងពលតូចលេខ៥៣

២ -អនុសេនីយ៍ត្រី **គាន់ ចិន** អត្តលេខ ០៤៤១១២ មេ.ការរង អនុ.តូច៣ វរសេនាតូច៥៣៣ កងពលតូចលេខ៥៣

៣ -នាយចំណាង់ **ម៉ុត ច័ន្ទដារា** អត្តលេខ ០៥២៧១៣ ជំនួយការ ភស្តុភារបច្ចេកទេស លេខាធិការដ្ឋាន កងពលតូចលេខ៥៣

៤ -នាយចំណាង់ **គាត សុផល** អត្តលេខ ០៧៣៨៧៦ បុគ្គលិក អប់រំចិត្តសាស្ត្រ ការិយាល័យទី៥ កងពលតូចលេខ៥៣

៥ -នាយចំណាង់ **ខែត ធូ** អត្តលេខ ០៥៣៩១៩ បុគ្គលិក អប់រំចិត្តសាស្ត្រ ការិយាល័យទី៥ កងពលតូចលេខ៥៣

៦ -ព្រិន្ទបាលឯក **អុន សាត** អត្តលេខ ០៩០១៧៧ បុគ្គលិក បំរើការ ការិយាល័យទី៥ កងពលតូចលេខ៥៣

៧ -ព្រិន្ទបាលឯក **ជន សុធារ៉ា** អត្តលេខ ០៨៣១៩៣ បុគ្គលិក បំរើការ ការិយាល័យទី៥ កងពលតូចលេខ៥៣

៨ -ព្រិន្ទបាលឯក **ផេង សុភី** អត្តលេខ ០៥២៩០០ បុគ្គលិក បំរើការ ការិយាល័យទី៥ កងពលតូចលេខ៥៣

៩ -ព្រិន្ទបាលឯក **សួស ម៉ុនណារិទ្ធ** អត្តលេខ ០៩០៥៨៩ បុគ្គលិក ចលនូបត្ថម្ភ អនុ.ធំគាំទ្រ កងពលតូចលេខ៥៣

១០ -ព្រិន្ទបាលឯក **យ៉ុង ដួង** អត្តលេខ ០៧៥៤៧២ មេក្រុម វរសេនាតូច៥៣៤ កងពលតូចលេខ៥៣

១១ -ព្រិន្ទបាលឯក **ឌិន ទ៉ុយ** អត្តលេខ ០៧៥៣៧៩ នាយរងក្រុម វរសេនាតូច៥៣៤ កងពលតូចលេខ៥៣

១២ -ព្រិន្ទបាលឯក **ថន ចល័ក្ខ** អត្តលេខ ១០៧៨៨៨ ពេទ្យ បឋមគិលានដ្ឋាន កងពលតូចលេខ៥៣

១៣ -ព្រិន្ទបាលឯក **ម៉ាត់ សំអាត** អត្តលេខ ០៦១៨០៣ បុគ្គលិកហ្វឹកហ្វឺន ការិយាល័យហ្វឹកហ្វឺន កងពលតូចលេខ៥៣

១៤ -ព្រិន្ទបាលឯក **សួស សារ៉ាត់** អត្តលេខ ០៨៣៣១៥ បុគ្គលិក ជួសជុលអាវុធធ្វើរជើង យ៥៣៤ កងពលតូចលេខ៥៣

១៥ -ព្រិន្ទបាលឯក **ចែម ម៉ន** អត្តលេខ ០៨១៩៥២ បុគ្គលិក បើកបរ អនុ.តូចដឹកជញ្ជូន យ៥៣៥ កងពលតូចលេខ៥៣

១៦ -ព្រិន្ទបាលឯក **ហ្លួយ ពៅ** អត្តលេខ ០៥៤១៧៦ នាយរងក្រុម អនុ.១ អនុ.ធំ២ យ៥៣៤ កងពលតូចលេខ៥៣

១៧ -ព្រិន្ទបាលទោ **ញ៉ឹម សារឿន** អត្តលេខ ០៧៥៣៩៨ បុគ្គលិក បំរើការ ការិយាល័យទី៥ កងពលតូចលេខ៥៣

១៨ -លោក **ម៉ាន់ លីហៀង** មន្ត្រីត្រួតពិនិត្យ ហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## គ-មេដាយសំរឹទ្ធការងារ

| | | | | | | |
|---|---|---|---|---|---|---|
| ១ | -វរសេនីយ៍ត្រី | យូ | ខ្លឹង | អត្តលេខ | ០១១៨៨៩ | នាយរងការិយាល័យទី២ កងពលតូចលេខ៥៣ |
| ២ | -វរសេនីយ៍ត្រី | ប៉ុល | តឹម | អត្តលេខ | ០០៣០៧២ | នាយរងការិយាល័យទី៣ កងពលតូចលេខ៥៣ |
| ៣ | -វរសេនីយ៍ត្រី | គាន | រី | អត្តលេខ | ១៩៨២៨៥ | ជំនួយការ ផ្នែកអត្តសញ្ញាប័ណ្ណ ការិយាល័យទី១ |
| ៤ | -អនុសេនីយ៍ឯក | ហេង | យាន | អត្តលេខ | ១០៨០៩២ | ជំនួយការហិរញ្ញវត្ថុ កងពលតូចលេខ៥៣ |
| ៥ | -អនុសេនីយ៍ឯក | កែ | យ៉ាត់ | អត្តលេខ | ០២១៤៣៣ | ជំនួយការភស្តុភារ វ.តូច៥៣៤ កងពលតូចលេខ៥៣ |
| ៦ | -អនុសេនីយ៍ឯក | ឡេង | ទ៉ុយ | អត្តលេខ | ០២១៤៤៣ | ជំនួយការវិស្វកម្ម វ.តូច៥៣១ កងពលតូចលេខ៥៣ |
| ៧ | -អនុសេនីយ៍ឯក | ឡៀន | ហ៊ី | អត្តលេខ | ០៥៤១០៣ | ជំនួយការហ្វឹកហ្វឺន ការិ.ហ្វឹកហ្វឺន កងពលតូចលេខ៥៣ |
| ៨ | -អនុសេនីយ៍ទោ | អ៊ឹង | ឡូត | អត្តលេខ | ០៤៤១៤១ | មេ.ការ អនុ.ធំ៣ វ.តូច៥៣៤ កងពលតូចលេខ៥៣ |
| ៩ | -អនុសេនីយ៍ទោ | ជយ | ឈុំ | អត្តលេខ | ០៣២៨០០ | ជំនួយការផែនការ ការិ.ហ្វឹកហ្វឺន កងពលតូចលេខ៥៣ |
| ១០ | -អនុសេនីយ៍ទោ | រស់ | សឿង | អត្តលេខ | ០៤២១០៩ | ជំនួយការហ្វឹកហ្វឺន ការិ.ហ្វឹកហ្វឺន កងពលតូចលេខ៥៣ |
| ១១ | -អនុសេនីយ៍ទោ | ឌី | ហាក់ | អត្តលេខ | ០២១៤៤១ | មេ.ការរង អនុ.ធំវិស្វកម្ម កងពលតូចលេខ៥៣ |
| ១២ | -អនុសេនីយ៍ទោ | កុសល | សុវណ្ណធីរៈ | អត្តលេខ | ១៣៧២៧១ | នាយទាហាន កងពលតូចអន្តរាគមន៍លេខ ១១ |
| ១៣ | -អនុសេនីយ៍ត្រី | ថោង | សុបញ្ញា | អត្តលេខ | ០៤០៣៨៦ | នាយទាហាន កងពលតូចអន្តរាគមន៍លេខ ១១ |
| ១៤ | -អនុសេនីយ៍ត្រី | ទន់ | ធី | អត្តលេខ | ០៣២៨៤៥ | មេ.ការរង អនុ.តូច អនុ.ធំវិស្វកម្ម កងពលតូចលេខ៥៣ |
| ១៥ | -អនុសេនីយ៍ត្រី | ប៊ុង | សុផាត | អត្តលេខ | ០៣២៨៤៨ | មេ.ការ អនុ.តូច អនុ.ធំវិស្វកម្ម កងពលតូចលេខ៥៣ |
| ១៦ | -អនុសេនីយ៍ត្រី | ទ៉ាន់ | សារឿន | អត្តលេខ | ១០៧៧៧៥ | មេ.ការរង អនុ.តូច១ អនុ.ធំការពារអាកាស កងពលតូចលេខ៥៣ |
| ១៧ | -អនុសេនីយ៍ត្រី | យ៉ម | ទី | អត្តលេខ | ០៣២៨៥១ | មេ.ការ អនុ.តូច អនុ.ធំវិស្វកម្ម កងពលតូចលេខ៥៣ |
| ១៨ | -នាយចំណង់ | ផាត់ | សុភ័ណ្ឌា | អត្តលេខ | ១៦២៨១៦ | បុគ្គលិក បំរើការ ការិ.ទី៣ កងពលតូចលេខ៥៣ |
| ១៩ | -នាយចំណង់ | ឃិន | សុជាតិ | អត្តលេខ | ០៥៤៣៨៨ | នាយពួក វរសេនាតូច៥៣៤ កងពលតូចលេខ៥៣ |
| ២០ | -នាយចំណង់ | លីម | ឈុនលី | អត្តលេខ | ០៧៥៥៣១ | យុទ្ធជន វរសេនាតូច៥៣៤ កងពលតូចលេខ៥៣ |
| ២១ | -នាយចំណង់ | កែ | ចេងហ៊ី | អត្តលេខ | ១៣១២៣៥ | មេបញ្ជាការរង អនុសេនាតូច កងពលតូចលេខ៥១ |
| ២២ | -នាយចំណង់ | គង់ | ទី | អត្តលេខ | ១១០១៣៣ | បុគ្គលិក ហ្វឹកហ្វឺន ការិ.ហ្វឹកហ្វឺន កងពលតូចលេខ៥៣ |
| ២៣ | -ព្រិន្ទបាលឯក | សៀវ | រតនា | អត្តលេខ | ០៨២២៨៧ | យុទ្ធជន ក្រុមទី៣ អនុ.ធំ១ វរសេនាតូច៥៣៣ កងពលតូចលេខ៥៣ |
| ២៤ | -ព្រិន្ទបាលឯក | ឃឹម | សារឿន | អត្តលេខ | ០៥៤៣០៨ | នាយក្រុម វរសេនាតូច៥៣៤ កងពលតូចលេខ៥៣ |
| ២៥ | -ព្រិន្ទបាលឯក | ឌុច | នី | អត្តលេខ | ០៥៤៣៨៤ | បុគ្គលិកពេទ្យ វរសេនាតូច៥៣៤ កងពលតូចលេខ៥៣ |
| ២៦ | -ព្រិន្ទបាលឯក | ឯក | ភី | អត្តលេខ | ០៥៤៣៥៥ | នាយពួក វរសេនាតូច៥៣៤ កងពលតូចលេខ៥៣ |
| ២៧ | -ព្រិន្ទបាលឯក | សុខ | ផាន់ណា | អត្តលេខ | ០៦១២៨៨ | គ្រូពេទ្យ គិលានដ្ឋាន កងពលតូចលេខ៥៣ |

| | | | | |
|---|---|---|---|---|
| ២៨ | -ព្រិន្ទបាលឯក | **ឡៀវ** | **ទី** | អត្តលេខ ០៧៣៨៣៩ បុគ្គលិក ហ្វឹកហ្វឺន ការិ.ហ្វឹកហ្វឺន កងពលតូចលេខ៥៣ |
| ២៩ | -ព្រិន្ទបាលទោ | **អ៊ុក** | **ឧុធថា** | អត្តលេខ ១៣១៣៦៩ ពេទ្យ បឋម គិលានដ្ឋាន កងពលតូចលេខ៥៣ |
| ៣០ | -លោកស្រី | **ចែ** | **ឡៀវ** | អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣១ | -លោក | **តាំង** | **ថេងហ៊ី** | អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣២ | -លោក | **លាត** | **អ៊ុន** | អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៣ | -លោក | **ផាន** | **ស** | អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៤ | -លោក | **ឃួន** | **ស៊ីណាត** | ប្រធានគ្រឿងចក្រ អូររំដួល ខេត្តបាត់ដំបង |
| ៣៥ | -លោក | **ឯក** | **សម្បត្តិ** | អាជីវករ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង |
| ៣៦ | -លោកស្រី | **ម៉ែន** | **លីមហៀង** | មេភូមិ កណ្តាល ឃុំទង់ ស្រុកសំឡូត ខេត្តបាត់ដំបង |

**មាត្រា២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ មេបញ្ជាការកងទ័ពជើងគោក និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ ០៤ ឆ្នាំ ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចមាត្រា១ និងមាត្រា២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយ
# ស្តីពី
# ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្ស
# នៅរដ្ឋបាលថ្នាក់ក្រោមជាតិ

# អារម្ភកថា

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានផ្តល់នូវក្របខ័ណ្ឌគតិយុត្តឲ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលជានីតិបុគ្គលសាធារណៈត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឲ្យមានចិរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ អនុលោមតាមគោលការណ៍នេះ តម្រូវឲ្យមានការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីអនុវត្តការងាររបស់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែលក្នុងនោះ ការរៀបចំឡើងវិញនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស គឺជាកិច្ចការដ៏មានសារសំខាន់ និងចាំបាច់មួយ។

ក្នុងន័យនេះ ដើម្បីផ្តល់នូវផែនទីបង្ហាញផ្លូវរយៈពេលវែង រាជរដ្ឋាភិបាលបានសម្រេចដាក់ចេញនូវ **ឯកសារគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ** ដោយបានកំណត់នូវគោលបំណង យុទ្ធសាស្ត្រនានា និងដំណាក់កាលជាក់លាក់សម្រាប់ការរៀបចំឡើងវិញ និងអនុវត្តនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយភាពប្រាកដប្រជា លើកកម្ពស់ភាពជាម្ចាស់ គណនេយ្យភាព ឆ្លើយតបបានយ៉ាងមានប្រសិទ្ធភាពទៅនឹងតម្រូវការអភិវឌ្ឍជាក់ស្តែងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្របតាមកិច្ចដំណើរការផ្ទេរមុខងារ និងធនធានទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងធានាសង្គតិភាពជាមួយកម្មវិធីកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល។

ក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ខ្ញុំសូមសម្តែងនូវការកោតសរសើរចំពោះគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលបានដឹកនាំសម្របសម្រួលក្នុងការរៀបចំឯកសារគោលនយោបាយដ៏មានសារសំខាន់នេះ និងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះដៃគូអភិវឌ្ឍន៍នានាដែលបានចូលរួមចំណែកគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងជំនួយបច្ចេកទេសក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ជាតិ។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ក្រសួង ស្ថាប័នថ្នាក់ជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធទាំងអស់នឹងបន្តការគាំទ្រ និងចូលរួមក្នុងការអភិវឌ្ឍ និងអនុវត្តនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមគោលការណ៍តម្រង់ទិសនៃឯកសារគោលនយោបាយនេះ ដើម្បីធានាដល់ការចូលរួមចំណែកសម្រេចបាននូវគោលបំណងនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យយ៉ាងពិតប្រាកដ។ 

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# មាតិកា


I. សេចក្តីផ្តើម ........ 01

II. និយមន័យ និងវិសាលភាព ........ 02

III. ចក្ខុវិស័យ ........ 03

IV. គោលបំណង និងគោលដៅ ........ 04

V. យុទ្ធសាស្ត្រ ........ 04

VI. ការអនុវត្ត ........ 08

VII. ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ ........ 10

VIII. សេចក្តីសន្និដ្ឋាន ........ 10

សន្ទានុក្រម ........ 12

## I. សេចក្តីផ្តើម

### ១. សាវតា

ចាប់ពីដើមទសវត្ស១៩៩០ រហូតដល់ការចាប់ផ្តើមនៃសហសវត្សថ្មី ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋមានការវិវត្តប្រែប្រួលយ៉ាងគំហុកដោយសារតែលទ្ធផលនៃនយោបាយផ្សះផ្សា និងបង្រួបបង្រួមជាតិក្រោមមគ្គុទេសក៍ប្រកបដោយគតិបណ្ឌិត និងភាពប៉ិនប្រសប់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ នយោបាយដ៏មានប្រសិទ្ធភាពមួយក្នុងចំណោមនយោបាយជាច្រើន ដែលនាំមកឲ្យកម្ពុជានូវសន្តិភាព និងការអភិវឌ្ឍនាបច្ចុប្បន្ននេះគឺ "**នយោបាយសមាហរណកម្ម**"។ ការធ្វើសមាហរណកម្មសំដៅដល់ការរួមបញ្ចូលគ្នានូវបុគ្គលិករដ្ឋបាលស៊ីវិល និងកងកម្លាំងប្រដាប់អាវុធពីគ្រប់ភាគីនយោបាយក្រោម "**យុទ្ធសាស្ត្រឈ្នះឈ្នះ**" របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី**។ ការធ្វើសមាហរណកម្មនេះ គឺជាកូនសោដែលនាំឲ្យបង្កើតបាននូវរដ្ឋបាលឯកភាពរបស់ជាតិតែមួយ។

ក្រោយសមាហរណកម្ម រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធិផលធំៗជាច្រើន ក្នុងនោះរួមមាន៖ ការបញ្ចប់សង្គ្រាម និងការបង្រួបបង្រួមជាតិ ការបង្កើតបាននូវឯកភាពជាតិ និងសន្តិភាពពេញផ្ទៃប្រទេស ការជំរុញ និងពន្លឿនដំណើរការអភិវឌ្ឍប្រទេស និងការផ្ទេរបញ្ចូលមន្ត្រីរាជការស៊ីវិលទៅក្នុងក្របខ័ណ្ឌថ្មីប្រកបដោយជោគជ័យ។

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការតាមរយៈការបង្កើតឲ្យមានក្រុមប្រឹក្សាឃុំ សង្កាត់ ដោយអនុលោមតាមច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ដែលបានអនុម័តនៅឆ្នាំ២០០១។ បន្ទាប់មក រាជរដ្ឋាភិបាលកម្ពុជា បានប្រកាសដាក់ឲ្យអនុវត្តជាផ្លូវការនូវក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៥។ ផ្តើមចេញពីក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ និងផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំតាក់តែង អនុម័ត និងដាក់ឲ្យអនុវត្ត។ ផ្អែកតាមច្បាប់រៀបចំអង្គការនេះ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌអាណត្តិទី១ ត្រូវបានរៀបចំឡើងនាឆ្នាំ២០០៩។

ជាងនេះទៅទៀត ច្បាប់រៀបចំអង្គការខាងលើនេះបានតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព សំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋ ដើម្បីសម្របសម្រួលនូវរាល់សកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ផ្អែកលើគោលការណ៍នេះតម្រូវឲ្យមានការរៀបចំកែសម្រួលប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋ។

ដើម្បីពិនិត្យមើលការអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិរបស់រាជរដ្ឋាភិបាល គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជា

ធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ត្រូវបានបង្កើតឡើង។ គណៈកម្មាធិការនេះ បានរៀបចំតាក់តែងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ រយៈពេល១០ឆ្នាំ (២០១០-២០១៩) ដែលត្រូវបានរាជរដ្ឋាភិបាលអនុម័ត នៅថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១០ និង ត្រូវបានប្រកាសឲ្យអនុវត្តជាផ្លូវការនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១០ នៅក្នុងវេទិកាជាតិមួយក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។

## ២. សនិទានភាព

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានតម្រូវឲ្យមានការពិនិត្យ និងធ្វើការកែសម្រួលនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សឡើងវិញស្របពេលជាមួយនឹងកិច្ចដំណើរការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបង្កើតឲ្យមានក្របខ័ណ្ឌបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

អាស្រ័យហេតុនេះ គោលនយោបាយនេះនឹងផ្តល់ជាគោលការណ៍ណែនាំសម្រាប់ការរៀបចំបង្កើតប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបទៅដោយភាពប្រាកដប្រជា ប្រសិទ្ធភាព ភាពជាម្ចាស់ និងឆ្លើយតបទៅតាមស្ថានភាពជាក់ស្តែង និងតាមការអភិវឌ្ឍរបស់ប្រទេសជាតិ។

ការរៀបចំ និងការអនុវត្តគោលនយោបាយស្តីពីការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាមធ្យោបាយដ៏មានសារៈសំខាន់មួយដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការបង្កើនប្រសិទ្ធភាព និងប្រសិទ្ធផលនៃការអនុវត្តគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ និងដើម្បីធានាឲ្យមានសង្គតិភាពជាមួយ៖

- ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់
- កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- កម្មវិធីកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ
- កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រក្នុងវិស័យមុខងារសាធារណៈ

## II. និយមន័យ និងវិសាលភាព

ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺសំដៅដល់ការអនុវត្តសកម្មភាពគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយប្រសិទ្ធភាព ផលិតភាព ឆ្លើយតបទៅនឹងតម្រូវការការងារ និងការប្រតិបត្តិនូវការពង្រឹង និងពង្រីកសមត្ថភាពបុគ្គលិក មន្ត្រីរាជការ តាមរយៈការអភិវឌ្ឍចំណេះដឹង ជំនាញ បទពិសោធន៍ ការផ្លាស់ប្តូរ អាកប្បកិរិយា និងឥរិយាបថរបស់មន្ត្រីរាជការពីអ្នកគ្រប់គ្រងទៅជាអ្នកផ្តល់សេវា ប្រកបដោយវប្បធម៌សេវាសាធារណៈ

ឆន្ទៈម្ចាស់ការ កក្តីភាព សីលធម៌ និងមនសិការវិជ្ជាជីវៈខ្ពស់។

អភិក្រមនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់ការធ្វើផែនការធនធានមនុស្ស ការគ្រប់គ្រងគុណផល ការជ្រើសរើស និងការប្រឡងជ្រើសរើស ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការ ប្រព័ន្ធលើកទឹកចិត្ត និងការដាក់វិន័យ ការដាក់ពង្រាយមន្ត្រីរាជការ ការឈប់សម្រាក ក្រមសីលធម៌វិជ្ជាជីវៈ ការរៀបចំប្រព័ន្ធលាភការ ការបណ្តុះបណ្តាល ការអភិវឌ្ឍអាជីព ការចាកចេញពីមុខងារសាធារណៈ និងរបបសន្តិសុខសង្គមនៃមន្ត្រីរាជការស៊ីវិល។ល។

បុគ្គលិកក្រុមប្រឹក្សា គឺជាបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលជាមន្ត្រីរាជការស៊ីវិល និងបុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិល។ បុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិលរួមមាន៖ មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលជាបុគ្គលិកសម្រាប់ជួយការងារដល់អង្គភាពនានាចំណុះក្រុមប្រឹក្សា ប៉ុន្តែមិនមែនជាមន្ត្រីរាជការក្របខ័ណ្ឌឡើយ។

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន៖

**១. បុគ្គលិកដែលត្រូវបានជ្រើសរើសនិងតែងតាំងដោយក្រុមប្រឹក្សា**

បុគ្គលិកទាំងនេះ គឺជាបុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សានៅពេលមានតម្រូវការធនធានមនុស្សដើម្បីបំពេញភារកិច្ច និងករណីយកិច្ចឆ្លើយតបទៅនឹងតម្រូវការការងារដែលក្រុមប្រឹក្សាត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**២. បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញ និងផ្ទេរទៅឱ្យក្រុមប្រឹក្សា**

បុគ្គលិកទាំងនេះរួមមាន៖

- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញតាមការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងមន្ត្រីរាជការដែលមានបច្ចុប្បន្នទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បុគ្គលិកដែលបានផ្ទេរពីក្រសួង ស្ថាប័នទៅឲ្យក្រុមប្រឹក្សាក្នុងដំណើរការផ្ទេរមុខងារ និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**៣. បុគ្គលិកដែលត្រូវបានតែងតាំងនិងចាត់តាំងឲ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា**

បុគ្គលិកទាំងនេះ គឺជាបុគ្គលិកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ហើយត្រូវបានចាត់តាំងឲ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិស្របតាមការកំណត់របស់រាជរដ្ឋាភិបាល។

គោលនយោបាយនេះ មានវិសាលភាពអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**III. ចក្ខុវិស័យ**

គោលនយោបាយនេះ មានចក្ខុវិស័យដើម្បីធានាការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកបដោយផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធិផលសំដៅឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការអភិវឌ្ឍប្រទេសជាតិ។

## IV. គោលបំណង និងគោលដៅ

### ១. គោលបំណង

គោលនយោបាយនេះ មានគោលបំណងផ្ដល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យកាន់តែមានសមត្ថភាព ផលិតភាព ភក្ដីភាព ឆន្ទៈម្ចាស់ការ គណនេយ្យភាព វប្បធម៌សេវាសាធារណៈ សីលធម៌ និងមនសិការវិជ្ជាជីវៈខ្ពស់។

### ២. គោលដៅ

គោលនយោបាយនេះ មានគោលដៅដូចខាងក្រោម៖

**ទីមួយ** ៖ បង្កើតឲ្យមានក្របខ័ណ្ឌបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទីពីរ** ៖ បង្កើតឲ្យមាន និងដាក់ឲ្យដំណើរការនូវប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលក្ខណៈជាអចិន្ត្រៃយ៍ឆ្លើយតបទៅតាមតម្រូវការជាក់ស្ដែងនៅថ្នាក់មូលដ្ឋាន និងដោយអនុលោមទៅតាមបទដ្ឋានជាតិ។

**ទីបី** ៖ ពង្រឹង និងពង្រីកសមត្ថភាពជំនាញ ចំណេះដឹង ចំណេះធ្វើ បទពិសោធន៍ សីលធម៌ និងមនសិការវិជ្ជាជីវៈ ព្រមទាំងការយល់ដឹងអំពីច្បាប់ គោលនយោបាយ និងបទដ្ឋានគតិយុត្តនានារបស់រាជរដ្ឋាភិបាល។

## V. យុទ្ធសាស្ត្រ

គោលនយោបាយនេះ ត្រូវអនុវត្តតាមយុទ្ធសាស្ត្រដូចខាងក្រោម៖

### ១. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅទី១

#### ក. ការរៀបចំក្របខ័ណ្ឌគតិយុត្តអន្តរកាល

ការរៀបចំក្របខ័ណ្ឌគតិយុត្តអន្តរកាល គឺជាការបង្កើតឡើងនូវគោលការណ៍ណែនាំ ឬនីតិវិធីជាបណ្ដោះអាសន្ននានា ដើម្បីគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ នៅមុនពេលដែលក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់គ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ និងអនុម័តជាផ្លូវការ។ ក្នុងដំណាក់កាលអន្តរកាលនេះ ត្រូវដាក់ចេញលិខិតបទដ្ឋានគតិយុត្ត គោលការណ៍ណែនាំ និងនីតិវិធីចាំបាច់នានាដែលផ្ដល់សិទ្ធិអំណាចមួយចំនួនដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ការចាត់ចែងនិងការប្រើប្រាស់ធនធានមនុស្សរបស់ខ្លួន។

ដើម្បីជានាឲ្យការអនុវត្តនូវលិខិតបទដ្ឋានគតិយុត្តអន្តរកាលនេះដោយរលូន និងប្រកបដោយប្រសិទ្ធភាពចាំបាច់ត្រូវ៖

- ផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តខាងលើដល់អ្នកពាក់ព័ន្ធ
- បង្កើតឲ្យមានក្រុមការងារគាំទ្រការអនុវត្តលិខិតបទដ្ឋានគតិយុត្ត
- វាយតម្លៃលទ្ធផលនៃការអនុវត្តលិខិតបទដ្ឋានគតិយុត្តអន្តរកាលដើម្បីដកពិសោធន៍ និង[illegible]

ជាធាតុចូលសម្រាប់រៀបចំក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍។

**ខ. ការរៀបចំក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍**

ដើម្បីសម្រេចឲ្យបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ និងដើម្បីអនុវត្តមុខងារដែលត្រូវបានផ្ទេរដោយក្រសួងស្ថាប័នថ្នាក់កណ្តាល រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់គ្រប់គ្រងបុគ្គលិករបស់ខ្លួន។ ដូច្នេះ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវ**មានលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ** ដែលត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម៖

- មានសង្គតិភាពជាមួយច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- ធានាដល់ការផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់ខ្លួន
- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធានានូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងសមធម៌
- បង្កលក្ខណៈងាយស្រួលក្នុងការផ្ទេរ និងផ្លាស់ប្តូរទៅវិញទៅមករវាងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ ព្រមទាំងការពារផលប្រយោជន៍នានារបស់មន្ត្រីទាំងនោះ
- ផ្តល់អាទិភាពដល់ស្ត្រី ជនជាតិដើមភាគតិច និងជនពិការក្នុងការជ្រើសរើសឲ្យចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល ការដំឡើងថ្នាក់ឬឋានន្តរស័ក្តិ ការតែងតាំងមុខតំណែង និងការផ្តល់ការលើកទឹកចិត្តផ្សេងៗទៀត។
- ធានាមិនឲ្យមានការបង្កើនចំនួនបុគ្គលិកមុខងារសាធារណៈ

លក្ខន្តិកៈដោយឡែកនេះ ចាំបាច់ត្រូវបញ្ជាក់ច្បាស់ពីស្ថានភាពសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដូចជា៖

- **ការត្រួតពិនិត្យលើថវិកា៖** ថវិកាសម្រាប់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត ត្រូវដាក់បញ្ចូលក្នុងថវិការបស់ក្រុមប្រឹក្សា និងគ្រប់គ្រងចាត់ចែងដោយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។
- **ការត្រួតពិនិត្យលើបុគ្គលិក៖** ការត្រួតពិនិត្យទៅលើចំនួនបុគ្គលិកទាំងអស់ និងលទ្ធភាពនៃការរៀបចំបុគ្គលិក ត្រូវស្ថិតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ។
- **ការជ្រើសរើស៖** ការធ្វើផែនការ និងការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងបុគ្គលិកជាប់កិច្ចសន្យា ត្រូវធ្វើឡើងដោយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដោយមានការត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់សំដៅធានាមិនឲ្យមានការបង្កើនចំនួនបុគ្គលិកមុខងារសាធារណៈ។
- **ការគ្រប់គ្រងគុណផល៖** បុគ្គលិករបស់ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

ជាមួយគ្នានេះដែរ ការផ្ទេរការគ្រប់គ្រងបុគ្គលិកដែលត្រូវធ្វើឡើងជាបណ្តើរៗ មុន និងក្រោយពេលដែលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្តជាផ្លូវការដោយត្រូវអនុវត្តតាមអភិក្រមដូចខាងក្រោម៖

- ការធ្វើប្រតិភូកម្មសិទ្ធិអំណាច ឬដែនសមត្ថកិច្ចក្នុងការគ្រប់គ្រងបុគ្គលិកទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការប្រគល់មុខងារ ភារកិច្ច ការទទួលខុសត្រូវ និងការធ្វើសេចក្តីសម្រេចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការធ្វើប្រតិភូកម្ម និងការប្រគល់មុខងារ ភារកិច្ច សិទ្ធិអំណាច ដែនសមត្ថកិច្ច និងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬ ប្រកាសតាមពេលវេលាសមស្រប។

ជាងនេះទៅទៀត ការរៀបចំលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមគោលការណ៍ខាងលើនេះ តម្រូវឲ្យមានការរៀបចំ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធដើម្បីឲ្យមានសង្គតិភាព ជាមួយនឹងលក្ខន្តិកៈដោយឡែកនេះ។

**២. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅទី២**

**ក. ការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

ការរៀបចំប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតទៅលើអភិក្រមសំខាន់ៗដូចខាងក្រោម៖

**ក.១. ការរៀបចំផែនការធនធានមនុស្ស**

ក្នុងការរៀបចំផែនការធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតជាសំខាន់ ទៅលើការពិនិត្យ និងកែសម្រួលអង្គការលេខរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ការពិពណ៌នាមុខតំណែង ការរៀបចំផែនការធនធានមនុស្សប្រចាំឆ្នាំ និងការបែងចែកការងារ និងភារកិច្ចឲ្យបានច្បាស់លាស់។

**ក.២. ការគ្រប់គ្រងគុណផល**

ការរៀបចំ និងអនុវត្តប្រព័ន្ធគ្រប់គ្រងគុណផលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវអនុវត្តតាមអភិក្រមដូចខាងក្រោម៖

- ការរៀបចំពិពណ៌នាមុខតំណែង
- ការបង្កើតគោលបំណង និងទិសដៅការងារច្បាស់លាស់ដោយផ្អែកលើការពិពណ៌នាមុខតំណែង
- ការកំណត់សូចនាករ និងលទ្ធផលរំពឹងទុក
- ការកំណត់ល័ក្ខខ័ណ្ឌការងារ និងកិច្ចសន្យាអនុវត្តការងារ
- ការរៀបចំផែនការការងារ និងផែនការសកម្មភាព
- ការវាយតម្លៃលើការអនុវត្តការងារ និងការធ្វើរបាយការណ៍ទៀងទាត់
- ការរៀបចំប្រព័ន្ធលើកទឹកចិត្ត និងការដាក់វិន័យ
- ការរៀបចំ និងអនុវត្តប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ

**ក.៣. ការអភិវឌ្ឍធនធានមនុស្ស**

ការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតាមអភិក្រម ដូចខាងក្រោម៖

- ការពិពណ៌នាអំពីប្រវត្តិសមត្ថភាពការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំការអភិវឌ្ឍធនធានមនុស្សតាមប្រព័ន្ធព័ត៌មានវិទ្យា
- ការកំណត់ពីតម្រូវការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងកំណត់រយៈពេលអប្បបរមាដែលមន្ត្រីម្នាក់ៗ ត្រូវទទួលការបណ្តុះបណ្តាលក្នុងមួយឆ្នាំ
- ការរៀបចំផែនការអភិវឌ្ឍធនធានមនុស្ស ដោយផ្អែកលើការវិភាគគម្លាតពីការគ្រប់គ្រងកម្លាំងពលកម្មក្នុងកម្រិតអង្គភាព
- ការអនុវត្តសកម្មភាពអភិវឌ្ឍធនធានមនុស្ស

**ក.៤. ការគ្រប់គ្រងបុគ្គលិក**

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្តោតទៅលើអភិក្រមដូចខាងក្រោម៖

- **ការជ្រើសរើស៖** ត្រូវរៀបចំឡើងដោយផ្អែកតាមផែនការដែលបានកំណត់ និងត្រូវជ្រើសរើសឡើងតាមគោលការណ៍ប្រកួតប្រជែងប្រកបដោយតម្លាភាព យុត្តិធម៌ សមធម៌ និងផ្អែកលើគុណសម្បត្តិស័ក្តិសម ដោយផ្តល់អាទិភាពដល់ស្ត្រី ជនពិការ និងជនជាតិដើមភាគតិចជាដើម
- **ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំង៖** ត្រូវរៀបចំបង្កើតគោលការណ៍ និងយន្តការសម្រាប់ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការតែងតាំង ដោយពិចារណាជាពិសេសលើអតីតភាពការងារ គុណសម្បត្តិ និងគុណផល
- **ការផ្ទេរ និងការផ្លាស់ប្តូរទីកន្លែងធ្វើការ៖** ត្រូវបង្កើតគោលកាណ៍ និងយន្តការសម្រាប់ការផ្ទេរ និងការផ្លាស់ប្តូរទីកន្លែងធ្វើការ
- **សីលធម៌ និងវិន័យ៖** ត្រូវរៀបចំក្រមសីលធម៌ និងកំណត់អំពីវិធាននិងយន្តការក្នុងការដាក់វិន័យឲ្យបានច្បាស់លាស់
- **ការចាកចេញពីអាជីព៖** ត្រូវកំណត់គោលការណ៍ចាកចេញពីមុខងារសាធារណៈសម្រាប់មន្ត្រីរាជការស៊ីវិល ដូចជា ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ ការសុំឈប់ដោយស្ម័គ្រចិត្ត វិធានការណ៍ខាងវិន័យ និងមរណភាពជាដើម ព្រមទាំងត្រូវកំណត់គោលការណ៍សម្រាប់ការបញ្ចប់ការងារបុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា និងបុគ្គលិកអណ្តែត។

**ខ. ការអនុវត្តប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃត្រូវកំណត់អំពីវិធាន និងគោលការណ៍ជាមូលដ្ឋាននានាសម្រាប់គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សក្នុងលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅទី៣

ដើម្បីពង្រឹង និងពង្រីកសមត្ថភាពជំនាញ ចំណេះដឹង និងបទពិសោធន៍ក្នុងការអនុវត្តប្រព័ន្ធ[illegible] សម្រាប់គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តដូចខាងក្រោម៖

ក. ដំណាក់កាលអន្តរកាល

**ក.១.** អភិវឌ្ឍសមត្ថភាពអំពីការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សដល់ទីចាត់ការធនធានមនុស្សនៅសាលារាជធានី ខេត្ត និងការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៅសាលាក្រុង ស្រុក ខណ្ឌ ដោយផ្តោតលើ៖

- ការរៀបចំផែនការ ការសម្របសម្រួល និងការរៀបចំវគ្គបណ្តុះបណ្តាល ដើម្បីពង្រឹងជំនាញគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស
- ការរៀបចំចងក្រងសៀវភៅណែនាំស្តីពីរបៀបប្រើប្រាស់ឧបករណ៍គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សផ្សេងៗគ្នា។

**ក.២.** អនុវត្តសាកល្បងនូវឧបករណ៍គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលបានកំណត់នៅចំណុច ក.១. ខាងលើ។

ខ. ដំណាក់កាលអចិន្ត្រៃយ៍

ខ.១. រៀបចំរចនាសម្ព័ន្ធគាំទ្រ សម្រាប់ការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សដោយ ៖

- អគ្គនាយកដ្ឋានពាក់ព័ន្ធនានានៃក្រសួងមុខងារសាធារណៈត្រូវផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងតាមដានការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ
- មន្ទីរមុខងារសាធារណៈនៅរាជធានី ខេត្ត ត្រូវជួយគណៈអភិបាលរាជធានី ខេត្ត ក្នុងការគ្រប់គ្រងមន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញការងារនៅថ្នាក់ក្រោមជាតិ និងដើម្បីផ្តល់ការគាំទ្រដល់ការអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិ
- ការបង្កើតវិទ្យាស្ថានជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងសាលារដ្ឋបាលមូលដ្ឋានថ្នាក់ភូមិភាគ
- ការពង្រីកមុខងារ និងសមត្ថភាពស្ថាប័នដែលមានស្រាប់ ជាពិសេសសាលាភូមិន្ទរដ្ឋបាល។

ខ.២. ផ្អែកតាមបទពិសោធន៍ដែលបានមកពីការអនុវត្តសាកល្បង ឧបករណ៍គ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សត្រូវដាក់ឲ្យអនុវត្តនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

## VI. ការអនុវត្ត

### ១. ស្ថាប័នអនុវត្ត និងស្ថាប័នពាក់ព័ន្ធ

- គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃជាស្ថាប័ននាំមុខក្នុងការអនុវត្តគោលនយោបាយនេះ
- អនុគណៈកម្មាធិការបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃ គ.ជ.អ.ប. មានភារកិច្ចដឹកនាំ តម្រង់ទិស និងសម្របសម្រួលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និងក្របខ័ណ្ឌគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- ក្រសួងមុខងារសាធារណៈ និងលេខាធិការដ្ឋាន គ.ជ.អ.ប. ជាសេនាធិការក្នុងការសម្របសម្រួលការអនុវត្ត
- ស្ថាប័នបង្គោលខាងលើនេះ ទទួលបន្ទុកសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តគោលនយោបាយនេះ។

**២. ការបង្កើតយន្តការ**

- គ.ជ.អ.ប. ក្រសួងមុខងារសាធារណៈ និងក្រសួងមហាផ្ទៃត្រូវសហការរៀបចំឲ្យមានស្ថាប័នបណ្តុះបណ្តាលនៅថ្នាក់ជាតិ (វិទ្យាស្ថានជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ) និងថ្នាក់ក្រោមជាតិ (សាលារដ្ឋបាលមូលដ្ឋានថ្នាក់ភូមិភាគ)
- ក្រសួងមុខងារសាធារណៈ ត្រូវរៀបចំឲ្យមានយន្តការគាំទ្រចាំបាច់នានាដូចជា ការបង្កើតមន្ទីរមុខងារសាធារណៈនៅរាជធានី ខេត្ត និងអង្គភាពគាំទ្រការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិនៃក្រសួងមុខងារសាធារណៈជាដើម។

**៣. ផែនការសកម្មភាព**

ស្ថាប័នអនុវត្តត្រូវរៀបចំផែនការសកម្មភាព ព្រមទាំងគម្រោងថវិការួម និងលម្អិតដែលត្រូវអនុវត្តតាមដំណាក់កាលនានាដូចខាងក្រោម៖

- ការរៀបចំ និងការដាក់ឲ្យអនុវត្តលិខិតបទដ្ឋានគតិយុត្តអន្តរកាល (២០១៣-២០១៤)
- ការរៀបចំ និងការអនុម័តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ(២០១៣-២០១៤)
- ការរៀបចំលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធផ្សេងៗទៀតសម្រាប់អនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ(២០១៣-២០១៤)
- ការផ្សព្វផ្សាយ ការដាក់ឲ្យអនុវត្ត និងការវាយតម្លៃក្នុងដំណាក់កាលអន្តរកាលនៃការអនុវត្តលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា (២០១៤-២០១៥)
- ការអភិវឌ្ឍស្ថាប័ន និងធនធានមនុស្ស(២០១៤-២០១៩)
- ការធ្វើវិសោធនកម្ម និងកែសម្រួលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា ដោយផ្អែកលើលទ្ធផលនៃការវាយតម្លៃទៅលើការអនុវត្តលិខិតបទដ្ឋានទាំងនេះក្នុងដំណាក់កាលអន្តរកាល ដើម្បីធានាដល់ការអនុវត្តនូវប្រព័ន្ធគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយភាពពេញលេញ និងមានប្រសិទ្ធភាព (២០១៦-២០១៩)។

**៤. ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ**

ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំផែនការថវិការបស់ខ្លួនសម្រាប់គាំទ្រដល់ការអនុវត្តសកម្មភាពពាក់ព័ន្ធនានាជាមួយនឹងគោលនយោបាយនេះ។

គ.ជ.អ.ប. ត្រូវខិតខំកៀរគរការគាំទ្រទាំងជំនួយបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា ដើម្បីចូលរួមចំណែកអនុវត្តគោលនយោបាយនេះ។

## VII. ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

គ.ជ.អ.ប.មានតួនាទីជាអ្នកតាមដាន ត្រួតពិនិត្យ និងវាយតម្លៃដំណើរការអនុវត្តគោលនយោបាយនេះ។ លេខាធិការដ្ឋាននៃ គ.ជ.អ.ប. គឺជាសេនាធិការរបស់ គ.ជ.អ.ប. ក្នុងការអនុវត្តតួនាទីនេះ។

## VIII. សេចក្តីសន្និដ្ឋាន

គោលនយោបាយនេះ បង្ហាញពីវឌ្ឍនភាពថ្មីមួយទៀត ក្នុងបរិការនៃការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ វឌ្ឍនភាពថ្មីនេះគឺជាការផ្លាស់ប្តូរវិធីសាស្ត្រនៃការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឲ្យមានសង្គតិភាពទៅនឹងក្របខ័ណ្ឌយុទ្ធសាស្ត្រវិមជ្ឈការនិងវិសហមជ្ឈការ គោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីចូលរួមចំណែកក្នុងដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាមួយគ្នានេះដែរ គោលនយោបាយនេះក៏បង្ហាញពីចក្ខុវិស័យក្នុងការបង្កើតឲ្យមានប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបង្ហាញពីគោលបំណង និងគោលដៅមួយចំនួន ដើម្បីធានាបាននូវការទ្រទ្រង់ និងពង្រឹងអភិបាលកិច្ចល្អក្នុងការគ្រប់គ្រង និងការអភិវឌ្ឍធនធានមនុស្សរបស់រដ្ឋ។ បន្ថែមពីលើនេះទៀត យុទ្ធសាស្ត្រសំខាន់ៗមួយចំនួនត្រូវបានកំណត់ និងដាក់ឲ្យអនុវត្ត ដើម្បីធានាថា ធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថភាពផ្តល់សេវាសាធារណៈនិងសេវារដ្ឋបាលប្រកបដោយគុណភាព មានវិជ្ជាជីវៈច្បាស់លាស់ មានមនសិការទទួលខុសត្រូវខ្ពស់ និងឆ្លើយតបតាមតម្រូវការជាក់ស្តែងរបស់មូលដ្ឋាន។

ការអនុវត្តយុទ្ធសាស្ត្រទាំងឡាយខាងលើនេះ គឺជាការកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់រាជរដ្ឋាភិបាលក្នុងការពង្រឹងភាពជាម្ចាស់ គណនេយ្យភាព ប្រសិទ្ធភាព និងប្រសិទ្ធផលក្នុងបរិការនៃការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ ជារួម គោលនយោបាយនេះនឹងរៀបចំឲ្យមាន៖

- **ទីមួយ៖** ក្របខ័ណ្ឌគតិយុត្តអចិន្ត្រៃយ៍សម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដែលឆ្លើយតបតាមតម្រូវការជាក់ស្តែងនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងបម្រើឲ្យផលប្រយោជន៍របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- **ទីពីរ៖** ប្រព័ន្ធគ្រប់គ្រងនិងអភិវឌ្ឍធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលបង្កលទ្ធភាពដល់ការសម្របសម្រួល និងពង្រឹងសកម្មភាពគ្រប់គ្រង និងអភិវឌ្ឍសមត្ថភាពធនធានមនុស្សក្នុងវិស័យមុខងារសាធារណៈ ប្រកបដោយសង្គតិភាពនិងប្រសិទ្ធភាព។

**ទីបី៖** ការពង្រឹងនិងពង្រីកការអនុវត្តយុទ្ធសាស្ត្រនៃការបញ្ជ្រាបយេនឌ័រ ក្នុងវិស័យមុខងារសាធារណៈនៅរដ្ឋបាលថ្នាក់ក្រោមជាតិឲ្យកាន់តែទូលំទូលាយ និងមានការយល់ដឹងជាសាធារណៈកាន់តែស៊ីជម្រៅ សំដៅប្រែក្លាយកម្លាំងពលកម្ម បញ្ញាញាណ និងការចូលរួមដ៏សកម្មទាំងបុរស និងស្ត្រីក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមនៅមូលដ្ឋាន ព្រមទាំងកិច្ចអភិវឌ្ឍប្រទេសតាមបែបប្រជាធិបតេយ្យប្រកបដោយវឌ្ឍនភាព វិបុលភាព និងសុខដុមនីយកម្ម។

**ទីបួន៖** ការចូលរួមយ៉ាងសកម្មក្នុងការពង្រឹង និងពង្រីកកិច្ចអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជននៅតាមមូលដ្ឋាន និងការពង្រឹងខឿនសេដ្ឋកិច្ច ដើម្បីធានានិរភាពនៃដំណើរការអភិវឌ្ឍប្រទេសតាមរយៈការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមនុស្សរបស់រដ្ឋបាលថ្នាក់ក្រោមជាតិប្រកបដោយផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផល។

ការរៀបចំ និងអនុវត្តយ៉ាងត្រឹមត្រូវនូវគោលនយោបាយនេះនឹងជួយជំរុញឲ្យប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជា អាចឆ្លើយតបទៅនឹងបរិការជាតិ តំបន់ និងសកលលោក។

សេចក្តីព្រាងឯកសារគោលនយោបាយនេះត្រូវបានពិនិត្យពិភាក្សា និងឯកភាព នៅក្នុងកិច្ចប្រជុំលើកទី៨ របស់ គ.ជ.អ.ប នាថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ និងត្រូវបានអនុម័តដោយរាជរដ្ឋាភិបាល

## សទ្ទានុក្រម

- **រដ្ឋបាលថ្នាក់ក្រោមជាតិ** ជាទូទៅសំដៅដល់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និង សង្កាត់។
- **វប្បធម៌សេវាសាធារណៈ** សំដៅដល់ការផ្តល់សេវាសាធារណៈរបស់បុគ្គលិក មន្ត្រីរាជការ ដែលត្រូវ ប្រកាន់ខ្ជាប់នូវគោលការណ៍ចំបងៗដូចជា (១) ការផ្លាស់ប្តូរឥរិយាបទរបស់មន្ត្រីរាជការពី "អ្នកត្រួតត្រាទៅជាអ្នកផ្តល់សេវា" (២) ជាអ្នកផ្តល់សេវាដែលផ្តោតទៅលើសេចក្តីត្រូវការជាក់ស្តែង របស់អ្នកប្រើប្រាស់សេវា និងត្រូវឆ្លើយតបប្រកបដោយមនសិការវិជ្ជាជីវៈ និងសេចក្តីថ្លៃថ្នូររបស់ មន្ត្រីរាជការ (៣)ជាអ្នកប្រឹក្សាយោបល់ ដែលត្រូវយកចិត្តទុកដាក់ផ្តល់ពត៌មាននិងពន្យល់ឲ្យបាន ច្បាស់លាស់ដល់ប្រជាពលរដ្ឋអំពីនីតិវិធី របៀបរបប និងបែបបទផ្សេងៗ នៃការផ្តល់សេវា និង (៤) ជាអ្នកសម្របសម្រួលទៅលើដំណើរការនៃការផ្តល់សេវា និងការមកទទួលសេវាទៅប្រើប្រាស់ដោយ ការកាត់បន្ថយនីតិវិធីស្មុគស្មាញ ការផ្តល់សេវាមានភាពសាមញ្ញ ខ្លី ទាន់ពេលវេលា និងមានភាពរលូន នៅក្នុងទម្រង់ការងារ ទាំងអស់។
- **ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល** សំដៅដល់ការធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខ័ណ្ឌ ការ តែងតាំង ការដំឡើងថ្នាក់ ការដំឡើងឋានន្តរស័ក្តិ ការរៀបចំឋានន្តរស័ក្តិជាថ្មី ការផ្លាស់ប្តូរកន្លែង ធ្វើការ ការផ្ទេរ ការដាក់ឲ្យនៅក្រៅក្របខ័ណ្ឌដើម ការដាក់ឲ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ការ បញ្ឈប់ពីការងារ ការបណ្តេញចេញពីការងារ ការចូលនិវត្តន៍ ការបន្ថយឋានន្តរស័ក្តិ ការបន្ថយថ្នាក់ ការ ព្យួរមុខងារដោយផ្អាកបៀវត្ស ការចូលបម្រើការងារជាថ្មី។ល។
- **ការផ្លាស់ប្តូរស្ថានភាពគ្រួសារ** សំដៅដល់ការបញ្ចូលកូន ឬ សហព័ទ្ធទៅក្នុងបន្ទុក ការលុបកូន លុបសហព័ទ្ធចេញពីបន្ទុក។
- **គុណផល** សំដៅដល់ការសម្រេចលទ្ធផលការងាររបស់មន្ត្រីស្របតាមផែនការសកម្មភាព និង លទ្ធផលរំពឹងទុក ដែលបានកំណត់ដោយប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពខ្ពស់។
- **សូចនាករ** សំដៅដល់ឧបករណ៍ដែលត្រូវបានបង្កើតឡើងសម្រាប់វាស់វែងលទ្ធផលការងារធៀបទៅ នឹងគោលបំណង គោលដៅ ផែនការការងារ ផែនការសកម្មភាព កិច្ចសន្យា ឬកិច្ចព្រមព្រៀងអនុ វត្តការងារ និងលទ្ធផលរំពឹងទុក។
- **ការពិពណ៌នាមុខតំណែង** សំដៅដល់ការកំណត់នូវភារកិច្ច និងការទទួលខុសត្រូវរបស់ មុខតំណែងនីមួយៗ។
- **ផែនការធនធានមនុស្ស** សំដៅដល់ការព្យាករណ៍ពីតម្រូវការធនធានមនុស្សក្នុងពេលបច្ចុប្បន្ន និងអនាគត ដើម្បីបម្រើឲ្យគោលបំណងជាយុទ្ធសាស្ត្ររបស់អង្គភាពឬស្ថាប័ន និងដើម្បីសម្រេចឲ្យ បានលទ្ធផលរំពឹងទុករបស់អង្គភាព ឬស្ថាប័ន។ ផែនការធនធានមនុស្សត្រូវផ្សារភ្ជាប់នឹងផែនការ យុទ្ធសាស្ត្រ និងផែនការប្រតិបត្តិរបស់អង្គភាពឬស្ថាប័ន។
- **សមធម៌** សំដៅដល់ការអនុវត្តដោយស្មើភាពផ្អែកលើលក្ខណៈវិនិច្ឆ័យច្បាស់លាស់ មិនរើសអើង មិន ប្រកាន់បក្សពួក និងគោរពតាមគោលការណ៍ច្បាប់។

- **ផលិតភាព** ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការប្រើប្រាស់ធនធានមនុស្ស សំដៅដល់ការចាត់ចែង និងប្រើប្រាស់ធនធានមនុស្សឲ្យត្រូវតាមការងារ មុខតំណែង គុណវុឌ្ឍិ និងត្រូវតាមពេលវេលានិង ទីកន្លែង ដែលនាំឲ្យផលិតបានលទ្ធផលខ្ពស់ ឬច្រើនជាងមុន ហើយប្រើប្រាស់ធនធាន និង មធ្យោបាយប្រកបដោយភាពសន្សំសំចៃឬប្រសិទ្ធភាពចំណាយ។ ប្រសិទ្ធផល សំដៅដល់លទ្ធផលចុង ក្រោយ ឬជាគុណភាពនៃ លទ្ធផលដែលមានឥទ្ធិពល ឬផលប៉ះពាល់រយៈពេលវែង។

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ [illegible] សហវ.ប្រក

ត មកពីរាជកិច្ចលេខ ៣៣, ៣៤, ៣៥

## ប្រកាស
## ស្តីពី
## ការដាក់ឱ្យប្រើប្រាស់គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
ıgkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

**ប្រការ១._**

ត្រូវបានដាក់ឱ្យប្រើប្រាស់នូវកម្រងគំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ និងស្ទង់តម្លៃ សម្រាប់លទ្ធកម្មទំនិញ និងសំណង់។

**ប្រការ២._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៣._**

រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានសហគ្រាសសាធារណៈ ប្រធានគ្រឹះស្ថានសាធារណៈរដ្ឋបាល និងប្រធានអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ធ្វើនៅរាជធានីភ្នំពេញថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៤

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**<u>ចម្លងជូន</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៣ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# លក្ខខណ្ឌនៃកិច្ចសន្យា

## ១-និយមន័យ

-ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ.................... ហៅថាភាគី "អ្នកម្ចាស់ការ" តំណាងដោយ.......................... មុខងារ.......................មានអាសយដ្ឋាន........................ ។

-ក្រុមហ៊ុន/សហគ្រាស.......................... ដែលបានចូលរួមដេញថ្លៃ ហើយដែលត្រូវបានជ្រើសរើសប្រគល់កិច្ចសន្យា ការងារសាងសង់/ជួសជុល........ ហៅថាភាគី "អ្នកទទួលការ" តំណាងដោយ ................ មុខងារ................. អាសយដ្ឋាន................. លេខទូរស័ព្ទ............. អ៊ីមែល............. ។

-ការងារសាងសង់/ជួសជុល........ ដែលអនុវត្តដោយភាគី "អ្នកទទួលការ" ហៅកាត់ថា "ការងារ" ។

-តម្លៃសរុបនៃ "ការងារ" ដែលចុះកិច្ចសន្យាហៅថា "តម្លៃកិច្ចសន្យា" ។

## ២- ភារកិច្ចរបស់ "អ្នកម្ចាស់ការ"

"អ្នកម្ចាស់ការ" ត្រូវទទួលខុសត្រូវលើការទូទាត់ "តម្លៃកិច្ចសន្យា" ជូន "អ្នកទទួលការ" តាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា បន្ទាប់ពីបានទទួលកំណត់ហេតុវាយតម្លៃលទ្ធផល "ការងារ" របស់គណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ និងលិខិតស្នើសុំទូទាត់របស់ "អ្នកទទួលការ" ។ "អ្នកម្ចាស់ការ" ត្រូវចាត់តាំងក្រុមការងារបច្ចេកទេសចុះត្រួតពិនិត្យលក្ខណៈបច្ចេកទេសជាមុន រួចធ្វើរបាយការណ៍ជូនគណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ ។

## ៣- ភារកិច្ចរបស់ "អ្នកទទួលការ"

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃយ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន ។ "អ្នកទទួលការ" ត្រូវអនុវត្ត "ការងារ" ដោយអនុលោមតាមលក្ខណៈបច្ចេកទេស គំនូសប្លង់ និងប្រតិទិនការងារដែលមានចែងនៅក្នុងកិច្ចសន្យា ។ ប្រតិទិនការងារ ត្រូវផ្អែកលើការអនុវត្តចំនួនថ្ងៃ ដោយមិនគិតថ្ងៃឈប់សម្រាកធម្មតា លើកលែងតែថ្ងៃឈប់សម្រាកទាំងឡាយណាដែលកំណត់ដោយច្បាប់ ។

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះរាល់ការខូចខាត ឬបាត់បង់សម្ភារៈ និងអគ្គិភ័យ ការរងរបួស ឬគ្រោះថ្នាក់ដល់អាយុជីវិតចំពោះបុគ្គលណាមួយ ក្នុងពេលអនុវត្តកិច្ចសន្យា ។ "អ្នកទទួលការ" ត្រូវទទួលខុសត្រូវផងដែរចំពោះសុវត្ថិភាពការងារនៅក្នុងការដ្ឋាន ។

## ៤- ទឹកដៃ និងសម្ភារៈ

រាល់ "ការងារ" ត្រូវប្រើទឹកដៃ និងសម្ភារៈ ដែលមានគុណភាពល្អ ហើយជាប្រភេទសមរម្យសម្រាប់ការងារធ្វើដោយដៃ ឬដោយគ្រឿងចក្រ ហើយត្រូវស្របតាមការលម្អិតក្នុងលក្ខណៈបច្ចេកទេស ។ ចំពោះសម្ភារៈដែលយកមកប្រើត្រូវមានការពិសោធន៍គុណភាព និងមានការឯកភាពពី "អ្នកម្ចាស់ការ" ជាមុនទើបអាចប្រើប្រាស់បាន ដោយឡែកចំពោះឧបករណ៍ដែលយកមកប្រើប្រាស់ក្នុងការអនុវត្ត "ការងារ" "អ្នកទទួលការ" ត្រូវទទួលខុសត្រូវក្នុងការទិញ ឬជួលយកមកប្រើប្រាស់ក្នុងការដ្ឋាន ។

**៥- ការការពារអគ្គិភ័យ**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការការពារអគ្គិភ័យនៅក្នុងការដ្ឋាន ដែលកំពុងអនុវត្តការងារ ។ ឧបករណ៍ពន្លត់អគ្គិភ័យត្រូវមានជាប្រចាំនៅក្នុងការដ្ឋាន "ការងារ" និងក្រោមការត្រួតពិនិត្យរបស់ "អ្នកទទួលការ" ក្នុងរយៈពេលអនុវត្ត "ការងារ" ។ "អ្នកទទួលការ" ត្រូវអនុវត្តដោយប្រុងប្រយ័ត្ន ចំពោះការប្រើប្រាស់ឧបករណ៍ ឬប្រតិបត្តិការដែលអាចបណ្តាលឱ្យឆាបឆេះដោយប្រការណាមួយ ។

"អ្នកទទួលការ" ត្រូវធានាថាកម្មកររបស់ខ្លួនទាំងអស់ ចេះប្រើឧបករណ៍ពន្លត់អគ្គិភ័យ ដែលត្រូវបានប្រគល់ឱ្យប្រើប្រាស់នៅក្នុងការដ្ឋានពេលមានអគ្គិភ័យ ។

**៦- ការគោរពបរិស្ថាន**

"អ្នកទទួលការ" ត្រូវធានាលើការខូចខាតតិចតួច ឬច្រើន ដែលបណ្តាលឱ្យប៉ះពាល់ដល់បរិស្ថានរុក្ខជាតិ រចនាសម្ព័ន្ធមានស្រាប់ និងផលប្រយោជន៍ផ្សេងៗ ។ រាល់ការចំណាយលើការជួសជុល/សាងសង់ឡើងវិញ និងការសងជម្ងឺចិត្ត ជាបន្ទុករបស់ "អ្នកទទួលការ" ។

**៧- ការចុះកិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឱ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឱ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ" ។ "អ្នកទទួលការសំណង់បន្ត" ត្រូវចុះកិច្ចសន្យាជាមួយ "អ្នកទទួលការសំណង់ដើម" មិនមែនចុះកិច្ចសន្យាជាមួយ "អ្នកម្ចាស់ការ" នោះទេ ។ ប្រសិនបើ "អ្នកទទួលការសំណង់បន្ត" មានកំហុសឆ្គងណាមួយ "អ្នកទទួលការសំណង់ដើម" ត្រូវទទួលខុសត្រូវទាំងស្រុង ដោយធានាថាកំហុសទាំងនោះត្រូវបានកែតម្រូវ ។ "អ្នកម្ចាស់ការ" មិនធ្វើការដោះស្រាយបញ្ហាណាមួយដោយផ្ទាល់ជាមួយ "អ្នកទទួលការសំណង់បន្ត" ឡើយ ។

"អ្នកទទួលការសំណង់ដើម" អាចចុះកិច្ចសន្យាបន្តទៅ "អ្នកទទួលការសំណង់បន្ត" នូវផ្នែកណាមួយនៃកិច្ចសន្យាដែលមានតម្លៃយ៉ាងច្រើនបំផុតសែសិប(៤០)ភាគរយ នៃតម្លៃកិច្ចសន្យា ដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ជាមុន ។ "អ្នកទទួលការសំណង់បន្ត" នោះ ត្រូវតែជាអ្នកទទួលការសំណង់ដែលស្ថិតនៅក្នុងបញ្ជីឈ្មោះអ្នកទទួលការសំណង់ ប្រភេទសមស្របទៅនឹងការងារចុះកិច្ចសន្យានោះ ។

**៨- ឃ្លាំងស្តុកសម្ភារៈ និងជម្រកស្នាក់នៅរបស់កម្មករ**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះឃ្លាំងស្តុកសម្ភារៈ និងត្រូវការពារនូវសម្ភារៈ បរិក្ខារសម្រាប់ "ការងារ" ទាំងអស់ នៅការដ្ឋានសម្រាប់រយៈពេលនៃការអនុវត្តកិច្ចសន្យា ។ "អ្នកទទួលការ" ត្រូវទទួលខុសត្រូវដោយខ្លួនឯង រាល់ការបាក់បែក ឬការបាត់បង់សម្ភារៈ ។ "អ្នកទទួលការ" ត្រូវសង់ជម្រកស្នាក់នៅសម្រាប់កម្មករឱ្យបានសមស្របតាមចំនួនកម្មកររបស់ខ្លួន ។

**៩- ការគោរពបទដ្ឋានបច្ចេកទេសសំណង់**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត ទំហំ ទិសខ្នាត... ជាដើម ។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឱ្យបានសមស្រប មុននឹងធ្វើការប្រគល់ ទទួលសំណង់ ។

ឯកសារដើម ... (ដើម...)

### ១០- ការបញ្ជាកែប្រែ

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ ។ ការកែប្រែនេះអាចមាន ៖

-ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា

-ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារៈអ្វីមួយទៅក្នុង "ការងារ"

-ការកែប្រែ ទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"

-ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ

-ការសាងសង់បន្ថែមណាមួយ

-ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ" ។

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការកែប្រែនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

### ១១- ការពន្យារពេលបញ្ចប់ "ការងារ"

"អ្នកទទួលការ" អាចស្នើសុំពន្យារពេលបញ្ចប់ "ការងារ" បានដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" នឹងពិនិត្យ និងសម្រេចលើការសុំពន្យារពេលបញ្ចប់ការងារមិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ" ។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការពន្យារពេលនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

### ១២- ការធ្វើតេស្តសាកល្បង

"អ្នកម្ចាស់ការ" ត្រូវធ្វើការផ្ទៀងផ្ទាត់ការងាររបស់ "អ្នកទទួលការ" និងជូនដំណឹងទៅ "អ្នកទទួលការ" អំពីវិកលភាពនានាដែលបានរកឃើញ ។ ការផ្ទៀងផ្ទាត់នេះមិនត្រូវធ្វើឱ្យប៉ះពាល់ដល់ការទទួលខុសត្រូវរបស់ "អ្នកទទួលការ" ឡើយ ។

"អ្នកម្ចាស់ការ" អាចណែនាំដល់ "អ្នកទទួលការ" ឱ្យធ្វើតេស្តសាកល្បងការងារណាមួយដែល "អ្នកម្ចាស់ការ" យល់ឃើញថាមានវិកលភាព ។

"អ្នកម្ចាស់ការ" អាចស្នើឱ្យ "អ្នកទទួលការ" ធ្វើតេស្តសាកល្បងលើការងារដែលមិនមានបញ្ជាក់នៅក្នុងលម្អិតលក្ខណៈបច្ចេកទេស ដើម្បីផ្ទៀងផ្ទាត់រកវិកលភាព ។ ប្រសិនបើការធ្វើតេស្តបង្ហាញថាមានវិកលភាព នោះ "អ្នកទទួលការ" ត្រូវទទួលរ៉ាប់រងក្នុងការទូទាត់សម្រាប់ការធ្វើតេស្ត និងសម្រាប់ការជួសជុលឡើងវិញ ។ ប្រសិនបើពុំមានវិកលភាពទេនោះ សោហ៊ុយចំណាយសម្រាប់ការធ្វើតេស្ត ជាបន្ទុករបស់ "អ្នកម្ចាស់ការ" ។

**១៣- ការសំអាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់"ការងារ" ។ "អ្នកទទួលការ" ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ" ។

**១៤- ការបញ្ចប់ការងារ**

"ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ ។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំ "អ្នកម្ចាស់ការ" នូវលិខិតបញ្ជាក់ពីការបញ្ចប់ការងារ ។ "អ្នកម្ចាស់ការ" នឹងចេញលិខិតបញ្ជាក់ពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើពី "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់ ។

**១៥- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល........ខែ(*សរសេរជាអក្សរ..........*) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ក្នុងករណីពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតី បណ្តាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ ។ ការចំណាយលើការសាងសង់/ជួសជុលខាងលើជាបន្ទុករបស់"អ្នកទទួលការ"ទាំងស្រុង ។ ប្រសិនបើក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ "អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ"អ្នកទទួលការ"ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។ ករណីពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ...... បណ្តាលមកពីប្រធានស័ក្តិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ" ។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់ ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**១៦- ការចុះបញ្ជីចំណាយនិងរបាយការណ៍**

"អ្នកទទួលការ" ត្រូវចុះបញ្ជីនូវវិក្កយប័ត្រទិញទំនិញ ឬចំណាយផ្សេងៗ ដែលបានប្រើ ឬក៏ដើម្បីអនុវត្តបញ្ចប់ការងារក្នុងកិច្ចសន្យា ហើយការចំណាយនោះត្រូវចុះបញ្ជីឱ្យបានត្រឹមត្រូវ សម្រាប់រាយការណ៍ជូនភាគី "អ្នកម្ចាស់ការ" និងរក្សាទុកសម្រាប់អ្នកត្រួតពិនិត្យ ប្រសិនបើចាំបាច់នៅពេលណាមួយក្នុងអំឡុងពេលអនុវត្តកិច្ចសន្យា ។

**១៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា "អ្នកទទួលការ" ត្រូវអនុញ្ញាតឱ្យ "អ្នកម្ចាស់ការ" ចូលមកការដ្ឋាន ដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត ។

**១៨- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្តាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេលដប់(១០)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស ។

*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបញ្ចប់កិច្ចសន្យានេះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។*

**១៩- ករណីប្រធានសក្តិ**

"ប្រធានសក្តិ" គឺជាព្រឹត្តិការណ៍ដែលមិនអាចគិតទុកមុនបាន ឬមិនអាចជៀសវាងបាន ហើយដែលមូលហេតុរបស់វា មិនបណ្តាលមកពីការធ្វេសប្រហែស ឬខ្វះការប្រុងប្រយ័ត្ន ដោយភាគី "អ្នកទទួលការ" ។ ព្រឹត្តិការណ៍ទាំងនេះ មានដូចជា សង្គ្រាម ការបះបោរ អគ្គិភ័យ ទឹកជំនន់ ជម្ងឺរាតត្បាត ការដាក់កម្រិតឱ្យនៅដាច់ពីគេ ឬការហ៊ុមព័ទ្ធការដឹកជញ្ជូន ។ល។

ការយឺតយ៉ាវ ឬការខកខានក្នុងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចសន្យា ដែលបណ្តាលពីករណីប្រធានសក្តិនេះ "អ្នកទទួលការ" មិនត្រូវបានទទួលរងនូវការផាកពិន័យ ឬរឹបអូសប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាឡើយ ។

**២០- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

"អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប នៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ.............. ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិលេខ...... ។

បន្ទាប់ពីបានកក់ប្រាក់រួច អ្នកដេញថ្លៃឈ្នះត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ.............. ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា ។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់ ។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះក្នុងបញ្ជីខ្មៅ ។

**២១- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់គឺជាប្រាក់រៀល ។ ការទូទាត់តម្លៃកិច្ចសន្យា ត្រូវធ្វើតាមរយៈ អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ...... ដោយបង្វែរចូលគណនីរបស់"អ្នកទទួលការ" លេខ............... នៅធនាគារ...................... ។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តជាក់ខាតបាន ត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ហេតុត្រួតពិនិត្យ វាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ (ព្រមទាំងមានការចូលរួមពី តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

ការទូទាត់ត្រូវធ្វើតាមដំណាក់កាលដូចខាងក្រោម ៖

**ដំណាក់កាលទី១** : នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន.......% (.....*សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន.......% (.....*សរសេរជាអក្សរ*) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ ចំនួន.............................. រៀល (*សរសេរជាអក្សរ*........................) ។

**ដំណាក់កាលទី២** : នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន.......% (.....*សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន.......% (.....*សរសេរជាអក្សរ*) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ ចំនួន.............................. រៀល (*សរសេរជាអក្សរ*.........................) ។

ដំណាក់កាលទី........ :

**២២- ការផាកពិន័យ**

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្តាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន ០,១០% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃដែលយឺតយ៉ាវ ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១០% នៃតម្លៃកិច្ចសន្យា ។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១០% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ចប់កិច្ចសន្យា ។

ក្នុងករណីដែលភាគី "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ/ មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ..... រតនាគារ....... ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន ០,០៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ ។

**២៣- ពន្ធ អាករ**

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយ អគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ........ នាពេលទូទាត់តម្លៃកិច្ចសន្យា ។

**២៤- ការទប់ទល់ នឹងការផ្តល់លាភសក្ការៈ**

"អ្នកទទួលការ" ត្រូវប្រកាសអះអាងថាខ្លួនពុំបានផ្តល់ ឬសន្យានឹងផ្តល់ប្រាក់ចំណាយ/ ផ្តល់អំណោយ ឬសក្ការៈណា មួយចំពោះមន្ត្រីនិយោជិតរដ្ឋាភិបាលណាមួយ ឬអ្នកដេញថ្លៃណាមួយដើម្បីទទួលបានកិច្ចសន្យា សកម្មភាពទាំងនេះ គឺជាមូលដ្ឋានគ្រប់គ្រាន់សម្រាប់ផ្អាក ឬលុបកិច្ចសន្យា ។

**២៥- ការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និង ភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នកម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

**២៦- សោហ៊ុយនាក់នងរឿងក្តី**

ក្នុងករណីមានរឿងក្តីក្តាំកើតឡើង ដែលបណ្តាលមកពីភាគី "អ្នកទទួលការ" រំលោភលើលក្ខខណ្ឌនានានៃកិច្ចសន្យាភាគី "អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះភាគី "អ្នកម្ចាស់ការ" រាល់ការចំណាយក្នុងការជួលមេធាវី។ ការចំណាយលើការខូចខាត និងចំណាយដទៃទៀតក្នុងរឿងក្តីនោះ ត្រូវកំណត់ដោយច្បាប់ ។

**២៧- ការប្រើប្រាស់ឯកសារកិច្ចសន្យា**

ប្រសិនបើគ្មានការយល់ព្រមពីភាគី "អ្នកម្ចាស់ការ" នោះ ភាគី "អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ។

ធ្វើនៅ................ ថ្ងៃទី ........ ខែ ........ ឆ្នាំ ..........

**ប្រធានអង្គភាពលទ្ធកម្ម**

បានឃើញ និង ឯកភាព

................ ថ្ងៃទី...........ខែ.............ឆ្នាំ ............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**និង្ឋាការរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

លេខ: ......................................សហវ.លសា

រាជធានីភ្នំពេញ ថ្ងៃទី .............. ខែ ............... ឆ្នាំ............

**បានឃើញ និងឯកភាព**

**រដ្ឋមន្ត្រី**

*(ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)*

ឧបសម្ព័ន្ធទី១

# គំនូសប្លង់

("អ្នកម្ចាស់ការ" ចាំបាច់ត្រូវរៀបចំឱ្យមានគំនូសប្លង់សំណង់ជាស្រេច
មុនរៀបចំឯកសារដេញថ្លៃ ហើយត្រូវភ្ជាប់ជាឧបសម្ព័ន្ធ)

បានឃើញ និង ឯកភាព

.................ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឧបសម្ព័ន្ធទី២

## លម្អិតលក្ខណៈបច្ចេកទេស

ការងារសាងសង់/ជួសជុល..........................................................................

- វាយសសរចាស់ចោល.........
- វាស់ប្រវែង កំណត់សសរ ប្រវែង៣.៥០ម សសរមួយ និង២៤ម សសរភ្លោះ.........
- ជីករណ្តៅគ្រឹះតាមគំនូសប្លង់ .........
- បោះថ្ម ៤ គុណ ៦ បាតរណ្តៅ .........
- លាយបាយអរចាក់បន្ទះក្បាលថ្ម.........
- ដាក់ចម្រឹងដែកចាក់បេតុង.........
- រៀបសសរចាក់បេតុង .........
- ចាក់ធ្នឹមក្រោម និងធ្នឹមសង្កត់តាមគំនូសប្លង់.........
- រៀបឥដ្ឋ១០.........
- បូក បៀក លាបស្តេត្រូល .........
- ដាក់ជើងទ្បៀន និងធ្នឹមសង្កត់.........
- ចាប់ជ្រីក្បាលសសរ.........

.....................

- សំអាតការដ្ឋាន

ធ្វើនៅ................ថ្ងៃទី...........ខែ............ឆ្នាំ .............

**ហត្ថលេខាអ្នកសិក្សាគម្រោង**

បានឃើញ និង ឯកភាព

............... ថ្ងៃទី...........ខែ............ឆ្នាំ .............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ឧបសម្ព័ន្ធទី៣

# ពាក្យសុំដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ............................................................ ភេទ ........................... សញ្ជាតិ ....................
ថ្ងៃ ខែ ឆ្នាំកំណើត ........................................... ទីកន្លែងកំណើត ..........................................................................
មុខងារ.............................................. តំណាងក្រុមហ៊ុន/សហគ្រាស.................... ដែលមានអាសយដ្ឋាន
.......................... ទូរស័ព្ទ ................. ទូរសារ/អ៊ីមែល ........................... គេហទំព័រ ...................... ។

**សូមគោរពជូន**

**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម.........**

**កម្មវត្ថុ** ៖ សំណើសុំចូលរួមដេញថ្លៃការងារសាងសង់/ជួសជុល.......................

**យោង** ៖ សេចក្តីជូនដំណឹងស្តីពីការអញ្ជើញចូលរួមដេញថ្លៃការងារសាងសង់/ជួសជុល................

សេចក្តីដូចមានក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម......... ជ្រាបថា ខ្ញុំបាទ/នាងខ្ញុំមានបំណងចូលរួមដេញថ្លៃការងារសាងសង់/ជួសជុល........................ ដោយដាក់តម្លៃដេញថ្លៃសរុបចំនួន.......................... (សរសេរជាអក្សរ .....................) ។ ចំនួនទឹកប្រាក់នេះមានបញ្ជាក់លម្អិតក្នុងបញ្ជីប៉ាន់តម្លៃ ដែលបានភ្ជាប់មកជាមួយ ។

សំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំមានសុពលភាព រយៈពេល.....*(បំពេញចំនួន)*.....ថ្ងៃ បន្ទាប់ពីថ្ងៃបើកសំណើដេញថ្លៃ ។

ប្រសិនបើសំណើដេញថ្លៃរបស់ខ្ញុំបាទ/នាងខ្ញុំបានទទួលជោគជ័យនោះ ខ្ញុំបាទ/នាងខ្ញុំនឹងបំពេញតាមគ្រប់នីតិវិធីដែលបានកំណត់ ព្រមទាំងគោរពឱ្យបានពេញលេញនូវលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា ។

សូមឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ទទួលនូវក្តីគោរពអំពីខ្ញុំបាទ/នាងខ្ញុំ ។

ធ្វើនៅ................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ហត្ថលេខាអ្នកដេញថ្លៃ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីប្រកាស
## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់អ្នកដេញថ្លៃ

ខ្ញុំបាទ/នាងខ្ញុំជាប្រធានក្រុមហ៊ុន/សហគ្រាស....... សូមធ្វើការអះអាងក្នុងការរៀបចំសំណើដេញថ្លៃលើការងារសាងសង់/ជួសជុល.......... ដូចខាងក្រោម ៖

១- មិនមាននិយោជិត សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូ ឬញាតិសន្តានរបស់ខ្ញុំបាទ/នាងខ្ញុំ មានទំនាក់ទំនងណាមួយដែលអាចចាត់ទុកថាជាទំនាស់ផលប្រយោជន៍ ពាក់ព័ន្ធនឹងការដេញថ្លៃនេះទេ។

២- ប្រសិនបើខ្ញុំបាទ/នាងខ្ញុំដឹងពីលទ្ធភាពដែលអាចកើតមាននូវទំនាស់ផលប្រយោជន៍នេះ ខ្ញុំបាទ/នាងខ្ញុំ នឹងរាយការណ៍ជាបន្ទាន់ជូនស្ថាប័នអនុវត្តលទ្ធកម្ម ។

៣- មិនមានការប្រព្រឹត្តអំពើពុករលួយ ក្លែងបន្លំ ឃុបឃិត ឬបង្ខិតបង្ខំ ទាក់ទិននឹងការដាក់សំណើដេញថ្លៃ របស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំ ។

៤- ខ្ញុំបាទ/នាងខ្ញុំយល់ច្បាស់ពីកាតព្វកិច្ចរបស់ខ្លួន ក្នុងការអនុញ្ញាតឱ្យស្ថាប័នមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ឬដៃគូអភិវឌ្ឍន៍ ធ្វើអធិការកិច្ចលើរាល់លិខិតស្នាមទាំងអស់ទាក់ទងនឹងការដាក់សំណើដេញថ្លៃរបស់ក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំនិងកិច្ចសន្យាណាមួយ ដែលជាលទ្ធផលនៃការដាក់ដេញថ្លៃនេះ ដោយមិនគិតថាក្រុមហ៊ុន/សហគ្រាសរបស់ខ្ញុំបាទ/នាងខ្ញុំបាន ឬមិនបានទទួលការសម្រេចប្រគល់កិច្ចសន្យានោះទេ ។

៥- គ្មានការទូទាត់ណាមួយ ទាក់ទងនឹងដំណើរការលទ្ធកម្មនេះ ត្រូវបានធ្វើឡើងដោយខ្ញុំបាទ/នាងខ្ញុំ សហការី ភ្នាក់ងារ ម្ចាស់ភាគហ៊ុន ទីប្រឹក្សា ដៃគូរបស់ខ្ញុំបាទ/នាងខ្ញុំ ឬញាតិសន្តានរបស់ពួកគេ ទៅឱ្យភ្នាក់ងារ ទីប្រឹក្សា និយោជិត ឬញាតិសន្តានរបស់ពួកគេ ដែលចូលរួមក្នុងដំណើរការលទ្ធកម្មនេះ ជំនួសមុខឱ្យស្ថាប័នអនុវត្តលទ្ធកម្ម អតិថិជន ឬនិយោជកនោះទេ ។

ធ្វើនៅ ................. ថ្ងៃទី ............. ខែ ............ ឆ្នាំ .............

ហត្ថលេខា

ឈ្មោះ.........................

៧ _ គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្នងតម្លៃ (ដេញថ្លៃ សំណង់) ទំព័រ 132/241

ឧបសម្ព័ន្ធទី៤

# បញ្ជីចាន់តម្លៃសរុប

ការងារសាងសង់/ជួសជុល....................................

| បរិយាយ | ទឹកប្រាក់ ( ជារៀល ) | ផ្សេងៗ |
|---|---|---|
| ១-ផ្នែកចំណាយទូទៅ : | ...................... | |
| -បញ្ជីលេខ ១ (ពលកម្ម) | ...................... | |
| -បញ្ជីលេខ ២ (សម្ភារៈ) | .................... | |
| ២-ផ្នែកចំណាយផ្សេងៗ : | ...................... | |
| -ដឹកជញ្ជូន | ...................... | |
| -សិក្សាគម្រោង | ...................... | |
| តម្លៃសរុប ( ១ + ២ ) | ............................ | |

បញ្ឈប់ត្រឹមទឹកប្រាក់ : ...................................................................................រៀល

(សរសេរជាអក្សរ ...........................................................................................................)។

ធ្វើនៅ................ ,ថ្ងៃទី............ខែ............ឆ្នាំ .............

**ហត្ថលេខាអ្នកដេញថ្លៃ**

គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្នង់តម្លៃ (ដេញថ្លៃ សំណង់) ទំព័រ ១..

ឧបសម្ព័ន្ធទី៤.១

# បញ្ជីប៉ាន់តម្លៃពលកម្ម

ការងារសាងសង់/ជួសជុល. .......................

បញ្ជីលេខ ១

| ល.រ | បរិយាយការងារ | ឯកតា | បរិមាណ | តម្លៃឯកតា (ជារៀល) | តម្លៃសរុប (ជារៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | ការងាររុះរើរបងចាស់ | មៅ | 1 | | | |
| ២ | ការងារជីករណ្តៅ | ម$^{៣}$ | 12.848 | | | |
| ៣ | ការងារចាក់ថ្នឹម | ម$^{៣}$ | 9.250 | | | |
| ៤ | ការងាររៀបឥដ្ឋ | ម$^{២}$ | 62.400 | | | |
| ៥ | ការងារបូកបាយអរ | ម$^{២}$ | 254.150 | | | |
| ៦ | ការងារលាបស្តេគ្រូលរបងថ្មី | ម$^{២}$ | 254.150 | | | |
| ៧ | ការងាររៀបបណ្តាញភ្លើង | ម | 51.390 | | | |
| ៨ | ការងារជ្រើក្បាលសរសរ | ដើម | 14 | | | |
| ៩ | ការងារលាបស្តេគ្រូលរបងចាស់ | ម$^{២}$ | 420 | | | |
| ១០ | ការងាររៀបគែមចិញ្ចើមស្មូន | ម | 61 | | | |
| ១១ | ការងាររៀបដើងទ្បេន | ដើម | 260 | | | |
| ... | .... | | | | | |
| | **សរុបបញ្ជីលេខ ១** | | | | | |

បញ្ឈប់ត្រឹមទឹកប្រាក់ : .............................................................................................រៀល

(សរសេរជាអក្សរ ...............................................................................................................) ។

ធ្វើនៅ................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ហត្ថលេខាអ្នកដេញថ្លៃ**

ឧបសម្ព័ន្ធទី៤.២

# បញ្ជីប៉ាន់តម្លៃសម្ភារៈ

ការងារសាងសង់/ជួសជុល.....................................

**បញ្ជីលេខ ២**

| ល.រ | បរិយាយសម្ភារៈ | ឯកតា | បរិមាណ | តម្លៃឯកតា (ជារៀល) | តម្លៃសរុប (ជារៀល) | ប្រភព |
|---|---|---|---|---|---|---|
| ១ | ស៊ីម៉ង់ត៍ | តោន | | | | |
| ២ | ដែកសរសៃគ្រប់ប្រភេទ | តោន | | | | |
| ៣ | លួសចំណង | គ.ក្រ | | | | |
| ៤ | ថ្ម ១ គុណ ២ | ម៣ | | | | |
| ៥ | ថ្ម ៤ គុណ ៦ | ម៣ | | | | |
| ៦ | ខ្សាច់រៀប បូក | ម៣ | | | | |
| ៧ | ក្តារពុម្ព និងរនូត | ម៣ | | | | |
| ៨ | កូនឈើធ្វើរន្ទា | ដើម | | | | |
| ៩ | ដែកគោល | សុង | | | | |
| ១០ | ឥដ្ឋប្រហោង | ដុំ | | | | |
| ១១ | ម្សៅបៀកជញ្ជាំងចំណុះ២៥គ.ក្រ/បាវ | បាវ | | | | |
| ១២ | ការស៊ីល័រ | ធុង | | | | |
| ១៣ | ស្តេត្រូល | ធុង | | | | |
| ១៤ | ក្រដាសខាត់ | សន្លឹក | | | | |
| ១៥ | រូឡូរុញស្តេត្រូល | ដើម | | | | |
| .... | ............. | | | | | |
| | **សរុបបញ្ជីលេខ ២** | | | | | |

បញ្ឈប់ត្រឹមទឹកប្រាក់ : ..........................................................................................រៀល

(សរសេរជាអក្សរ .......................................................................................................)។

ធ្វើនៅ................ ថ្ងៃទី............ខែ.............ឆ្នាំ

**ហត្ថលេខាអ្នកដេញថ្លៃ**

ឧបសម្ព័ន្ធទី៥

# ប្រតិទិនការងារ

ការងារសាងសង់/ជួសជុល.................................................................

| ល.រ | បរិយាយការងារ | ខែទី១ | | | | ខែទី២ | | | | ខែទី៣ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ស.ទី ១ | ស.ទី ២ | ស.ទី ៣ | ស.ទី ៤ | ស.ទី ១ | ស.ទី ២ | ស.ទី ៣ | ស.ទី ៤ | ស.ទី ១ | ស.ទី ២ | ស.ទី ៣ | ស.ទី ៤ |
| ១ | បើកការដ្ឋាន | | | | | | | | | | | | |
| ២ | ការងាររំាយរបងចាស់ | | | | | | | | | | | | |
| ៣ | ការងារជីករណ្តៅ | | | | | | | | | | | | |
| ៤ | ការងារចាក់ធ្លឹម | | | | | | | | | | | | |
| ៥ | ការងាររៀបឥដ្ឋ | | | | | | | | | | | | |
| ៦ | ការងារបូកបាយអរ | | | | | | | | | | | | |
| ៧ | ការងារលាបស្តេត្រូលរបងថ្មី | | | | | | | | | | | | |
| ៨ | ការងាររៀបបណ្តាញភ្លើង | | | | | | | | | | | | |
| ៩ | ការងារជ្រីក្បាលសរសរ | | | | | | | | | | | | |
| ១០ | ការងារលាបស្តេត្រូលរបងចាស់ | | | | | | | | | | | | |
| ១១ | ការងាររៀបគែមចិញ្ចើមសួន | | | | | | | | | | | | |
| ១២ | ការងាររៀបជើងទ្បៀន | | | | | | | | | | | | |
| ...... | ....... | | | | | | | | | | | | |
| ..... | សំអាតការដ្ឋាន | | | | | | | | | | | | |

មួយខែមានបួនសប្តាហ៍

ធ្វើនៅ................ ថ្ងៃទី...........ខែ............ឆ្នាំ ............

**ហត្ថលេខាអ្នកដេញថ្លៃ**

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ សំណង់) ទំព័រ 136/241*

ឧបសម្ព័ន្ធទី ៦

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

# លិខិតធានា
# ប្រាក់កក់ធានាការដេញថ្លៃ

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម......**

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស ........................................... មានបំណងដាក់សំណើដេញថ្លៃដើម្បីធ្វើការងារសាងសង់/ជួសជុល...................... ដែលត្រូវបើកសំណើដេញថ្លៃនៅថ្ងៃទី......... ខែ........ឆ្នាំ..................។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ............ សូមធានាចំពោះមុខគណៈកម្មាធិការលទ្ធកម្ម......................នូវប្រាក់កក់ធានាការដេញថ្លៃចំនួន .................................. (សរសេរជាអក្សរ..................................)។

ក្នុងករណីមានលក្ខខណ្ឌណាមួយកើតមានឡើងក្នុងចំណោមលក្ខខណ្ឌទាំងបីខាងក្រោម ៖

១-ប្រសិនបើអ្នកដេញថ្លៃ ដកសំណើដេញថ្លៃរបស់ខ្លួន ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

២-ប្រសិនបើអ្នកដេញថ្លៃ បដិសេធការចុះហត្ថលេខាលើកិច្ចសន្យា ក្នុងរយៈពេលសុពលភាពនៃសំណើដេញថ្លៃ

៣-ប្រសិនបើអ្នកដេញថ្លៃ មិនព្រមកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ។

នោះអគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ............ នឹងធ្វើការបង្វែរចូលថវិការដ្ឋនូវចំនួនប្រាក់កក់ខាងលើ នៅពេលដែលបានទទួលលិខិតស្នើសុំពីគណៈកម្មាធិការលទ្ធកម្ម ដែលបញ្ជាក់ថាអ្នកដេញថ្លៃមិនគោរពតាមលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងបីខាងលើ ។

លិខិតធានាប្រាក់កក់ធានាការដេញថ្លៃនេះមានសុពលភាព រយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ ក្រោយសុពលភាពសំណើដេញថ្លៃ ។

................. ថ្ងៃទី............. ខែ ............. ឆ្នាំ.............

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**

ឧបសម្ព័ន្ធទី ៧

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ** .............

# លិខិតធានា
# ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ/លោក/លោកស្រី ប្រធានគណៈកម្មាធិការលទ្ធកម្ម**...............

ដោយហេតុថាក្រុមហ៊ុន/សហគ្រាស.................................................... បានទទួលលិខិតស្តីពីការចុះកិច្ចសន្យាការងារសាងសង់/ជួសជុល...................... លេខ ............. ចុះថ្ងៃទី....... ខែ ........... ឆ្នាំ............. ដែលមានតម្លៃកិច្ចសន្យាចំនួន........................... (សរសេរជាអក្សរ............................................) ។

ដោយមានចែងនៅក្នុងលិខិតស្តីពីការចុះកិច្ចសន្យាថា "អ្នកទទួលការ" ត្រូវផ្តល់លិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ............. ដែលមានតម្លៃទឹកប្រាក់ស្មើនឹងដប់ (១០%) ភាគរយ នៃតម្លៃកិច្ចសន្យាសរុប ដើម្បីធានាការអនុវត្តកាតព្វកិច្ចស្របតាមលក្ខខណ្ឌកិច្ចសន្យា ។

អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ......... សូមធានា និងទទួលខុសត្រូវ នូវប្រាក់កក់ចំនួន........................ (សរសេរជាអក្សរ ......................................................) ។

ប្រាក់កក់ខាងលើនេះ នឹងត្រូវបង្វែរចូលថវិការដ្ឋ នៅពេលបានទទួលលិខិតស្នើសុំពី "អ្នកម្ចាស់ការ" ដែលបញ្ជាក់ថា "អ្នកទទួលការ" មិនគោរពតាមលក្ខខណ្ឌនៃកិច្ចសន្យា ហើយក្រុមហ៊ុន/សហគ្រាស .............................. ................................. គ្មានសិទ្ធិប្រកែក ឬតវ៉ាឡើយ ។

លិខិតធានានេះមានសុពលភាពរហូតដល់ក្រោយរយៈពេលធានាគុណភាពសំណង់ជាស្ថាពរ ។

.............. ថ្ងៃទី ........... ខែ........... ឆ្នាំ...........
**អគ្គនាយកដ្ឋានរតនាគារជាតិ/រតនាគារ**............

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

**បញ្ជីឈ្មោះអ្នកទិញឯកសារដេញថ្លៃ**
**ស្តីពីការងារសាងសង់/ជួសជុល....**

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | លេខទូរស័ព្ទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

................ ថ្ងៃទី...........ខែ............ឆ្នាំ .............
**ប្រធានអង្គភាពលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

## បញ្ជីឈ្មោះអ្នកដាក់សំណើដេញថ្លៃ
## ស្តីពីការទារសាងសង់/ជួសជុល....

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | លេខទូរស័ព្ទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

.................ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានអង្គភាពលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

**បញ្ជីវត្តមាន**
**អ្នកចូលរួមបើកសំណើរដេញថ្លៃ**
**ស្តីពីការទារសាងសង់/ជួសជុល ......................**
ថ្ងៃទី ........... ខែ ................ ឆ្នាំ ....................

| ល.រ | នាម និងគោត្តនាម | ភេទ | មុខងារ | ស្ថាប័ន/អង្គភាព | ហត្ថលេខា | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ...... | | | | | | |
| | | | | | | |

................ ថ្ងៃទី...........ខែ............ឆ្នាំ .............

**ប្រធានអង្គប្រជុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

## កំណត់ហេតុបើកសំណើដេញថ្លៃ
## ស្តីពីការងារសាងសង់/ជួសជុល ......................

ឆ្នាំពីរពាន់......... ខែ......... ថ្ងៃទី.......... វេលាម៉ោង................ នៅ.................. មានកិច្ចប្រជុំបើកសំណើដេញថ្លៃស្តីពីការងារសាងសង់/ជួសជុល................ ក្រោមអធិបតីភាព...................... ។

-ប្រភេទលទ្ធកម្ម .................................

-វិធីសាស្ត្រលទ្ធកម្ម .................................

-ប្រភពឥណទាន .................... ក្នុងផែនការឆ្នាំ ............ ជំពូក ......... គណនី ................ អនុគណនី ............

-កាលបរិច្ឆេទលក់ឯកសារដេញថ្លៃ : ចាប់ពីថ្ងៃទី.........ខែ........ឆ្នាំ ....... ដល់ថ្ងៃទី...........ខែ............ឆ្នាំ .........

-កាលបរិច្ឆេទទទួលសំណើដេញថ្លៃ: ចាប់ពីថ្ងៃទី...........ខែ............ឆ្នាំ ............ រៀងរាល់ម៉ោងធ្វើការ

-កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ: ថ្ងៃទី...........ខែ............ឆ្នាំ ............ វេលាម៉ោង...............

-អត្រាប្តូរប្រាក់ ១ដុល្លារ=................រៀល នៅថ្ងៃទី...........ខែ............ឆ្នាំ ............

១-ការលក់ឯកសារដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

២-ការទទួលសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ភេទ | កាលបរិច្ឆេទ<br>ម៉ោង....ថ្ងៃទី....ខែ....ឆ្នាំ...... | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៣-ការបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ប្រាក់កក់ធានាការដេញថ្លៃ | តម្លៃដាក់ដេញថ្លៃសរុប | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | ប្រាក់រៀល | ប្រាក់ដុល្លារ | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៤-ការតវ៉ា ឬបាតុភាពក្នុងពេលបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ប្រភេទនៃការតវ៉ា |
|---|---|---|
| ១ | | |
| ២ | | |
| ៣ | | |
| ...... | | |

៥-តំណាងផ្លូវការរបស់អ្នកដេញថ្លៃចូលរួមបើកសំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | ឈ្មោះអ្នកតំណាង | ហត្ថលេខា | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

៦-សមាសភាពគណៈកម្មាធិការលទ្ធកម្មចូលរួមបើកសំណើដេញថ្លៃ:

| ល.រ | នាម និងគោត្តនាម | មុខងារ | ហត្ថលេខា | សេចក្តីផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

កិច្ចប្រជុំបើកសំណើដេញថ្លៃត្រូវបានបញ្ចប់ នៅថ្ងៃទី............ខែ.............ឆ្នាំ ............ វេលាម៉ោង ..........

ធ្វើនៅ................ ថ្ងៃទី ........ ខែ ..........

**ប្រធានអង្គភាពលទ្ធកម្ម**

បានឃើញ និង ឯកភាព

.............. ថ្ងៃទី ............. ខែ.........ឆ្នាំ .................

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## សេចក្តីប្រកាស
## ស្តីពីក្រមសីលធម៌លទ្ធកម្មរបស់គណៈកម្មាធិការលទ្ធកម្ម

យើងខ្ញុំសូមធ្វើការអះអាងថា ៖

១- ក្នុងអំឡុងពេលដំណើរការលទ្ធកម្ម និងការវាយតម្លៃសំណើដេញថ្លៃ យើងខ្ញុំប្រកាន់ខ្ជាប់នូវក្រមសីលធម៌លទ្ធកម្មដូចមានបញ្ជាក់នៅក្នុងសៀវភៅលទ្ធកម្ម ស្តីពីការអនុវត្តវិធាននិងបទប្បញ្ញត្តិ ស្តីពីលទ្ធកម្មសាធារណៈ ។

២- នៅក្នុងការអនុវត្តតួនាទីរបស់យើងខ្ញុំ យើងខ្ញុំពុំទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារៈ ពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេ ក្រៅអំពីប្រាក់បៀវត្សផ្លូវការដែលយើងខ្ញុំបានទទួលក្នុងឋានៈជាមន្ត្រីរាជការ ។

៣- តាមដែលយើងខ្ញុំបានដឹង គ្មានសហសេវិក សហការី ឬញាតិសន្តាន បានទទួលនូវផលប្រយោជន៍ ទោះជារូបិយវត្ថុ ឬជាសម្ភារៈពីសំណាក់ស្ថាប័នខាងក្រៅ អ្នកដេញថ្លៃ ឬទីប្រឹក្សាណាមួយនោះទេក្រៅអំពីប្រាក់បៀវត្សផ្លូវការ ។

៤- យើងខ្ញុំមិនបានដឹងអំពីការអនុវត្តដែលកេងបន្លំ ពុករលួយ ឃុបឃិត ឬបង្ខិតបង្ខំនានា ដែលបានកើតឡើង នៅក្នុងដំណើការលទ្ធកម្មនោះទេ ហើយយល់យ៉ាងច្បាស់ថា យើងខ្ញុំមានកាតព្វកិច្ចខាងសីលធម៌ក្នុងការរាយការណ៍អំពីការអនុវត្តបែបនេះ ប្រសិនបើយើងខ្ញុំបានដឹង ។

៥- គ្មានទំនាស់ផលប្រយោជន៍ណាមួយកើតឡើង ទោះជាចំពោះយើងខ្ញុំ ឬចំពោះអ្នកដេញថ្លៃ ឬទីប្រឹក្សាដែលត្រូវបានសម្រេចប្រគល់កិច្ចសន្យាឱ្យ ឬចំពោះសហសេវិក សហការី និងញាតិសន្តាននោះទេ ។

ធ្វើនៅ ................. ថ្ងៃទី ............. ខែ ............ ឆ្នាំ .............

-ឈ្មោះ....................... (ហត្ថលេខា)

-ឈ្មោះ ....................... (ហត្ថលេខា)

-ឈ្មោះ....................... (ហត្ថលេខា)

-ឈ្មោះ ....................... (ហត្ថលេខា)

.........................

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ....**

## កំណត់ហេតុ
## ស្តីពី
## ការវាយតម្លៃប្រគល់កិច្ចសន្យា

ឆ្នាំពីរពាន់.......... ខែ.......... ថ្ងៃទី.......... វេលាម៉ោង................ នៅ.................. មានកិច្ចប្រជុំវាយតម្លៃប្រគល់កិច្ចសន្យាស្តីពីការងារសាងសង់/ជួសជុល................ ក្រោមអធិបតីភាព...................... ។

-ប្រភេទលទ្ធកម្ម ..................................
-វិធីសាស្ត្រលទ្ធកម្ម ..................................
-ប្រភពឥណទាន ..................... ក្នុងផែនការឆ្នាំ ............. ជំពូក .......... គណនី ................. អនុគណនី ............
-កាលបរិច្ឆេទលក់ឯកសារដេញថ្លៃ : ចាប់ពីថ្ងៃទី.........ខែ........ឆ្នាំ ....... ដល់ថ្ងៃទី............ខែ............ឆ្នាំ .........
-កាលបរិច្ឆេទទទួលសំណើដេញថ្លៃ: ចាប់ពីថ្ងៃទី...........ខែ............ឆ្នាំ ............ រៀងរាល់ម៉ោងធ្វើការ
-កាលបរិច្ឆេទឈប់ទទួល និងបើកសំណើដេញថ្លៃ: ថ្ងៃទី...........ខែ............ឆ្នាំ ............ វេលាម៉ោង...............
-អត្រាប្តូរប្រាក់ ១ដុល្លារ=................រៀល នៅថ្ងៃទី...........ខែ............ឆ្នាំ ............

១-ឈ្មោះក្រុមហ៊ុន/សហគ្រាសដែលបានដាក់សំណើដេញថ្លៃ:

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | កាលបរិច្ឆេទ ទិញឯកសារដេញថ្លៃ | កាលបរិច្ឆេទ ដាក់សំណើដេញថ្លៃ | ផ្សេងៗ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

**២-តារាងតម្លៃសំណើដេញថ្លៃ:**

| ល.រ | ឈ្មោះក្រុមហ៊ុន/ សហគ្រាស | ប្រាក់កក់ ធានាការដេញថ្លៃ | តម្លៃដាក់ដេញថ្លៃសរុប | | សេចក្តីផ្សេងៗ |
|---|---|---|---|---|---|
| | | | ប្រាក់រៀល | ប្រាក់ដុល្លារ | |
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ...... | | | | | |

៣- តារាងបង្ហាញភាពឆ្លើយតបតាមការណែនាំ នៃឯកសារដេញថ្លៃ :

| **សេចក្តីណែនាំអំពីលក្ខខណ្ឌ** | ក្រុមហ៊ុន/<br>សហគ្រាស... | ក្រុមហ៊ុន/<br>សហគ្រាស... | ក្រុមហ៊ុន/<br>សហគ្រាស... |
|---|---|---|---|
| ១-ការបិទភ្ជិត និងកាខ្ចងលើស្រោមសំបុត្រ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ២-ភាសានៃសំណើដេញថ្លៃ | ខ្មែរ | ខ្មែរ | ខ្មែរ |
| ៣-ចំនួនច្បាប់នៃសំណើដេញថ្លៃ | ០៣ច្បាប់ | ០៣ច្បាប់ | ០៣ច្បាប់ |
| ៤-ពាក្យសុំដេញថ្លៃ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ៥-គម្រូ និងការចុះហត្ថលេខាលើសំណើដេញថ្លៃ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ៦-គំនូសប្លង់ និងលម្អិតលក្ខណៈបច្ចេកទេស | មាន/គ្មាន | មាន/គ្មាន | មាន/គ្មាន |
| ៧-បញ្ជីប៉ាន់តម្លៃ *(សរុប-ពលកម្ម-សម្ភារៈ)* | គ្រប់គ្រាន់/<br>មិនគ្រប់គ្រាន់ | គ្រប់គ្រាន់/<br>មិនគ្រប់គ្រាន់ | គ្រប់គ្រាន់/<br>មិនគ្រប់គ្រាន់ |
| ៨-រយៈពេលសាងសង់/ជួសជុល<br>(ប្រតិទិនការងារ) | ....ថ្ងៃ | ....ថ្ងៃ | ....ថ្ងៃ |
| ៩-ឯកសារភ្ជាប់សំណើដេញថ្លៃ ៖ | | | |
| *-អត្តសញ្ញាណប័ណ្ណ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-ប័ណ្ណប៉ាតង់ឆ្នាំដេញថ្លៃ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្រចុះបញ្ជីអាករលើតម្លៃបន្ថែម អ.ត.ប (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្រប្រកបអាជីវកម្ម ចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| *-វិញ្ញាបនប័ត្រចុះបញ្ជីអ្នកទទួលការសាងសង់ ចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ចម្លងត្រឹមត្រូវតាមច្បាប់ដើម)* | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ | ត្រឹមត្រូវ/មិនត្រឹមត្រូវ |
| ១០-ប្រាក់កក់ធានាការដេញថ្លៃ ៖ | | | |
| *ក-ចំនួន* | .......រៀល/ដុល្លារ | .......រៀល/ដុល្លារ | .......រៀល/ដុល្លារ |
| *ខ-រយៈពេលសុពលភាព* | .....ថ្ងៃ | .....ថ្ងៃ | .....ថ្ងៃ |
| ១១-រយៈពេលសុពលភាពនៃសំណើដេញថ្លៃ | .....ថ្ងៃ | .....ថ្ងៃ | .....ថ្ងៃ |
| ១២-តម្រូវការក្រុមហ៊ុនរកស៊ីចូលគ្នា | មាន/គ្មាន | មាន/គ្មាន | មាន/គ្មាន |

| | | | |
|---|---|---|---|
| ១៣-តម្រូវការផ្សេងទៀត (ប្រសិនបើមាន) | ......... | ......... | ........... |
| ភាពឆ្លើយតបនៃសំណើដេញថ្លៃ | ពេញលេញ | ឆ្លើយតបច្រើន | ឆ្លើយតបតិច |

**៤-តារាងឈ្មោះក្រុមហ៊ុន/សហគ្រាសដែលមិនបានយកមកវាយតម្លៃ :**

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | មូលហេតុដែលមិនបានយកមកវាយតម្លៃ |
|---|---|---|
| ១ | ..... | ....... |
| ២ | ..... | |
| ៣ | | |
| ...... | | |

**៥-តារាងកែតម្រូវលេខនព្វន្ត :**

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | តម្លៃដាក់ដេញថ្លៃ | តម្លៃកែតម្រូវលេខនព្វន្តរួច | ផ្ទេរជាប្រាក់រៀល |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ...... | | | | |

៦-ឈ្មោះក្រុមហ៊ុន/សហគ្រាស ដែលបានដាក់សំណើដេញថ្លៃសមស្រប និងត្រូវបានយកមកវាយតម្លៃ (រៀបតាមលំដាប់តម្លៃដាក់ដេញថ្លៃ ពីទាបទៅខ្ពស់) :

| ល.រ | ឈ្មោះក្រុមហ៊ុន/សហគ្រាស | តម្លៃដាក់ដេញថ្លៃ | ផ្សេងៗ |
|---|---|---|---|
| ១ | | | |
| ២ | | | |
| ៣ | | | |
| ...... | | | |

**៧-ការសម្របសម្រួលតម្លៃតាមបច្ចេកទេស :**

| បរិយាយបច្ចេកទេស | តម្លៃតាមបច្ចេកទេស | ក្រុមហ៊ុន/សហគ្រាស... | ក្រុមហ៊ុន/សហគ្រាស... | ក្រុមហ៊ុន/សហគ្រាស... |
|---|---|---|---|---|
| ១-តម្លៃដាក់ដេញថ្លៃបន្ទាប់ពីបានកែតម្រូវលេខនព្វន្តរួច | | | | |
| ២-សម្របសម្រួលសម្រាប់ : | | | | |
| -ពន្ធ អាករ | | | | |
| -ការខុសគ្នាខាងបច្ចេកទេស : | | | | |

| | | | | |
|---|---|---|---|---|
| *+ពលកម្ម* | | | | |
| *+សម្ភារៈ* | | | | |
| *+ដឹកជញ្ជូន* | | | | |
| *+សិក្សាគម្រោង* | | | | |
| -ការប្រែប្រួលនៃលក្ខខណ្ឌទូទាត់ | | | | |
| -ការប្រែប្រួលរយៈពេលសាងសង់/ជួសជុល | | | | |
| -បញ្ចុះតម្លៃ(អប្បហា) | | | | |
| ៣-តម្លៃដែលត្រូវបានវាយតម្លៃរួច | | | | |
| ៤-ចំណាត់ថ្នាក់អ្នកដេញថ្លៃនាំមុខ | | លេខ | លេខ | លេខ |

**៨-ការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយ :**

គណៈកម្មាធិការលទ្ធកម្ម បានធ្វើការត្រួតពិនិត្យលក្ខណសម្បត្តិតាមក្រោយរបស់អ្នកដេញថ្លៃនាំមុខទី១ (*ឬបន្តបន្ទាប់ ក្នុងករណីអ្នកដេញថ្លៃនាំមុខទី១ មិនឆ្លើយតប*) ដោយធ្វើការផ្ទៀងផ្ទាត់ឡើងវិញលើឯកសារភស្តុតាងនានា ដើម្បីធានាភាពត្រឹមត្រូវ នៃតម្រូវការផ្លូវច្បាប់ តម្រូវការសមត្ថភាព "ហិរញ្ញវត្ថុ បច្ចេកទេស បទពិសោធន៍" ជាមួយនឹងស្ថានភាពជាក់ស្តែង បង្ហាញថាអ្នកដេញថ្លៃនាំមុខទី ... មានលក្ខណសម្បត្តិគ្រប់គ្រាន់ក្នុងការអនុវត្តកិច្ចសន្យា ។

**<u>សន្និដ្ឋាន</u>**

គណៈកម្មាធិការលទ្ធកម្ម បានឯកភាពសម្រេចប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន/សហគ្រាស ...................... ក្នុងតម្លៃកិច្ចសន្យាចំនួន...................... (សរសេរជាអក្សរ.................................. ) ដែលទាបជាងឥណទានធានាចំណាយចំនួន.................................. ។

អង្គប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង..........ថ្ងៃ..........ខែ........ឆ្នាំ............ ក្រោមស្មារតីយកចិត្តទុកដាក់ និងទទួលខុសត្រូវខ្ពស់ ។

ធ្វើនៅ................ ថ្ងៃទី ........ ខែ ........ ឆ្នាំ ..........

**ប្រធានអង្គភាពលទ្ធកម្ម**

សមាសភាពគណៈកម្មាធិការចូលរួម:

១-.............. (ហត្ថលេខា)

២-.............. (ហត្ថលេខា)

៣-.............. (ហត្ថលេខា)

......

បានឃើញ និង ឯកភាព

................ ថ្ងៃទី ............ ខែ..........ឆ្នាំ ............

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ........../............

**ជម្រាបមក**
**លោក/លោកស្រី ប្រធានក្រុមហ៊ុន/សហគ្រាស ..................**

**កម្មវត្ថុ** ៖ ការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្ដីពីការងារសាងសង់/ជួសជុល.............................. ។
**យោង** ៖ កំណត់ហេតុបើកសំណើដេញថ្លៃចុះថ្ងៃទី......... ខែ.......... ឆ្នាំ......... និងកំណត់ហេតុវាយតម្លៃប្រគល់កិច្ចសន្យាចុះថ្ងៃទី............ ខែ........... ឆ្នាំ........ របស់គណៈកម្មាធិការលទ្ធកម្ម............។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/លោកស្រីប្រធាន ក្រុមហ៊ុន/សហគ្រាស........... ជ្រាបថា ដោយផ្អែកលើកំណត់ហេតុវាយតម្លៃរបស់គណៈកម្មាធិការលទ្ធកម្ម........................ (ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ) សម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាជូនក្រុមហ៊ុន/សហគ្រាស ................ ដើម្បីធ្វើការងារសាងសង់/ជួសជុល........................................ ក្នុងតម្លៃទឹកប្រាក់សរុបចំនួន .................................... (សរសេរជាអក្សរ .......................................) ជាតម្លៃកិច្ចសន្យា ។

សូមលោក/លោកស្រីប្រធាន មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

................ ថ្ងៃទី .............. ខែ..........ឆ្នាំ ..................

**ហត្ថលេខា**
**ប្រធានស្ថាប័ន និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចម្លងជូន**

-...............
-..................
-..................
*-ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ........../.............

**ជម្រាបមក**
**លោក/លោកស្រី ប្រធានក្រុមហ៊ុន/សហគ្រាស** ...................

**កម្មវត្ថុ** ៖ ការចុះកិច្ចសន្យាស្តីពីការងារសាងសង់/ផ្គត់ផ្គង់/ជួសជុល.............................. ។
**យោង** ៖ លិខិតលេខ........ ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ......... ស្តីពីការសម្រេចជ្រើសរើស និងប្រគល់កិច្ចសន្យាស្តីពីការងារសាងសង់/ផ្គត់ផ្គង់/ជួសជុល.............................. ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ សូមលោក/លោកស្រីប្រធាន ក្រុមហ៊ុន/សហគ្រាស............ អញ្ជើញមកចុះកិច្ចសន្យាស្តីពីការងារសាងសង់/ផ្គត់ផ្គង់/ជួសជុល................................. នៅអង្គភាពលទ្ធកម្ម..................... ក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃយ៉ាងយូរបន្ទាប់ពីបានទទួលលិខិតនេះ ដោយភ្ជាប់មកជាមួយនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ចេញដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ...... ដែលមានតម្លៃទឹកប្រាក់ស្មើនឹង ១០% នៃតម្លៃកិច្ចសន្យាសរុប ។

សូមលោក/លោកស្រីប្រធាន មេត្តាទទួលនូវការរាប់អានអំពីខ្ញុំ ។

................ ថ្ងៃទី ............. ខែ..........ឆ្នាំ ..................
**ហត្ថលេខា**
**ប្រធានស្ថាប័ន និងជាប្រធានគណៈកម្មាធិការលទ្ធកម្ម**

**ចម្លងជូន**
-...............
-..................
-..................
*-ឯកសារ-កាលប្បវត្តិ*

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ សំណង់) ទំព័រ 150/241*

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ...**
**គណៈកម្មាធិការលទ្ធកម្ម**
លេខ ........../.............

# កិច្ចសន្យា
## ស្តីពី

ការងារសាងសង់/ជួសជុល ..........................................

កិច្ចសន្យានេះធ្វើឡើងរវាង ៖

-ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ........ តំណាងដោយ ........................ មុខងារ...................... មានអាសយដ្ឋាន .................... ត្រូវបានទទួលស្គាល់ថាជា "អ្នកម្ចាស់ការ" និង

-ក្រុមហ៊ុន/សហគ្រាស .................... តំណាងដោយ ........................... មុខងារ......................... ដែលចាប់ពីពេលនេះតទៅហៅថា "អ្នកទទួលការ" មានអាសយដ្ឋាន .................. លេខទូរស័ព្ទ............... អ៊ីមែល.............. ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាចុះកិច្ចសន្យាដូចមានចែងក្នុងប្រការខាងក្រោម ៖

**ប្រការ១- ទំហំការងារ និង តម្លៃកិច្ចសន្យា**

"អ្នកម្ចាស់ការ" និង "អ្នកទទួលការ" យល់ព្រមប្រគល់ ទទួលអនុវត្តការងារសាងសង់/ជួសជុល............ ......... ដែលហៅកាត់ថា "ការងារ" ដែលមានតម្លៃទឹកប្រាក់សរុបចំនួន............................. (សរសេរជាអក្សរ ............................................) ជាតម្លៃកិច្ចសន្យា ។

**ប្រការ២- កាលបរិច្ឆេទចាប់ផ្តើម និង បញ្ចប់ "ការងារ"**

"អ្នកទទួលការ" ត្រូវចាប់ផ្តើមអនុវត្ត "ការងារ" ក្នុងរយៈពេលប្រាំពីរថ្ងៃយ៉ាងយូរ ក្រោយពីកិច្ចសន្យាចូលជាធរមាន និងត្រូវបញ្ចប់ក្នុងរយៈពេល..........ថ្ងៃ (*សរសេរជាអក្សរ*......ថ្ងៃ) ស្របតាមប្រតិទិនការងារដែលបានស្នើឡើងដោយ "អ្នកទទួលការ" ហើយត្រូវបានយល់ព្រមដោយ "អ្នកម្ចាស់ការ" ។

**ប្រការ៣- ឯកសារឧបសម្ព័ន្ធនៃកិច្ចសន្យា**

- លិខិតសម្រេច ប្រគល់កិច្ចសន្យា
- បញ្ជីប៉ាន់តម្លៃ (សរុប-ពលកម្ម-សម្ភារៈ)
- លម្អិតលក្ខណៈបច្ចេកទេស
- គំនូសប្លង់ និងប្រតិទិនការងារ
- លក្ខខណ្ឌនៃកិច្ចសន្យា
- ឯកសារពាក់ព័ន្ធដទៃទៀត ។

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ សំណង់) ទំព័រ 151/241*

**ប្រការ៤- ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា**

"អ្នកទទួលការ" ត្រូវកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា ដែលមានទឹកប្រាក់ស្មើនឹងដប់(១០)ភាគរយ នៃតម្លៃកិច្ចសន្យាសរុប នៅធនាគារជាតិនៃកម្ពុជា ឬសាខាធនាគារជាតិ.............. ឬធនាគារពាណិជ្ជដែលបានចុះអនុស្សារណៈជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងគណនីរបស់អគ្គនាយកដ្ឋានរតនាគារជាតិលេខ...... ។

បន្ទាប់ពីបានកក់ប្រាក់រួច "អ្នកទទួលការ"ត្រូវស្នើសុំអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ.............. ចេញនូវលិខិតធានាប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា (មានទម្រង់ និងខ្លឹមសារដូចក្នុងគំរូភ្ជាប់ជាមួយឯកសារដេញថ្លៃ) រួចប្រគល់ជូន "អ្នកម្ចាស់ការ" មុនពេលចុះកិច្ចសន្យា ។

ការខកខានក្នុងការកក់ប្រាក់ធានាការអនុវត្តកិច្ចសន្យា គឺជាមូលដ្ឋានគ្រប់គ្រាន់ក្នុងការរឹបអូសប្រាក់កក់ធានាការដេញថ្លៃ ។

ប្រាក់កក់នេះត្រូវប្រគល់ជូន "អ្នកទទួលការ" វិញ យ៉ាងយូរក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃ ក្រោយពេលផុតរយៈពេលធានាគុណភាពសំណង់ ។

ក្នុងករណី "អ្នកទទួលការ" មិនបានអនុវត្តតាមប្រការណាមួយនៃកិច្ចសន្យា ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យានេះនឹងត្រូវរឹបអូសបង់ចូលថវិការដ្ឋ ហើយនឹងត្រូវបានកំណត់ថាជាមុខសញ្ញាសម្រាប់ការចុះឈ្មោះក្នុងបញ្ជីខ្មៅ ។

**ប្រការ៥- ការចុះកិច្ចសន្យាបន្ត**

ការចុះកិច្ចសន្យាបន្តនៃកិច្ចសន្យាទាំងមូលមិនត្រូវបានអនុញ្ញាតជាដាច់ខាត ។ "អ្នកទទួលការ" អាចចុះកិច្ចសន្យាបន្តឱ្យ "អ្នកទទួលការសំណង់បន្ត" ដើម្បីឱ្យអនុវត្តផ្នែកណាមួយនៃកិច្ចសន្យាបាន ដរាបណាមានការយល់ព្រមពី "អ្នកម្ចាស់ការ" ។ ក្នុងករណីដែល "អ្នកម្ចាស់ការ" យល់ព្រម ចំពោះការចុះកិច្ចសន្យាបន្ត ការយល់ព្រមនោះក៏មិនអាចបន្ធូរបន្ថយកាតព្វកិច្ចរបស់ "អ្នកទទួលការ" ដែលមានចែងក្នុងកិច្ចសន្យាដើមឡើយ ។

**ប្រការ៦- ការគោរពបទដ្ឋានបច្ចេកទេសសំណង់**

"អ្នកទទួលការ" ត្រូវទទួលខុសត្រូវចំពោះការគោរពបទដ្ឋានបច្ចេកទេស ទម្រង់ រចនាបថនៃសំណង់ និងត្រូវធានាចំពោះភាពត្រឹមត្រូវនៃទីតាំងសំណង់ និងភាពត្រឹមត្រូវនៃសំណង់ រួមមានកម្រិត កម្ពស់ ទំហំខ្នាត... ជាដើម ។ ក្នុងរយៈពេលសាងសង់/ជួសជុល "អ្នកទទួលការ" ត្រូវកែតម្រូវរាល់កំហុសទាំងឡាយឱ្យបានសមស្រប មុននឹងធ្វើការប្រគល់ ទទួលសំណង់ ។

**ប្រការ៧-ការត្រួតពិនិត្យការដ្ឋាន**

ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យា "អ្នកទទួលការ" ត្រូវអនុញ្ញាតឱ្យ "អ្នកម្ចាស់ការ" ចូលការដ្ឋានដើម្បីពិនិត្យលើការងារដែលកំពុងអនុវត្ត ។

**ប្រការ៨- ការបញ្ជាកែប្រែ**

ក្នុងរយៈពេលអនុវត្ត "ការងារ" "អ្នកម្ចាស់ការ" អាចធ្វើការកែប្រែគុណភាព ឬបរិមាណនៃការងារ ។ ការកែប្រែនេះអាចមាន ៖

-ការបង្កើន ឬបន្ថយបរិមាណការងារដែលមានចែងក្នុងកិច្ចសន្យា

-ការដកចេញ ឬការដាក់បញ្ចូលនូវសម្ភារៈអ្វីមួយទៅក្នុង "ការងារ"

-ការកែប្រែទំហំ ខ្នាតនៃផ្នែកណាមួយនៃ "ការងារ"

-ការកែប្រែរចនាបថ ឬប្រភេទនៃការងារណាមួយ

-ការសាងសង់បន្ថែមណាមួយ

-ការកែប្រែនូវលំដាប់ ឬរយៈពេលនៃសកម្មភាព"ការងារ" ។

ប្រសិនបើភាគី "អ្នកទទួលការ" ទទួលយកនូវការផ្លាស់ប្តូរនេះតាមលក្ខខណ្ឌដែលបានព្រមព្រៀងគ្នា ឯកសារកែប្រែនឹងក្លាយជាឯកសារឧបសម្ព័ន្ធបន្ថែមនៃកិច្ចសន្យា ដោយរក្សាតម្លៃកិច្ចសន្យានៅដដែល ។

**ប្រការ៩- ការពន្យារពេលបញ្ចប់ "ការងារ"**

"អ្នកទទួលការ" អាចស្នើសុំពន្យារពេលបញ្ចប់ "ការងារ" បានដោយមានការយល់ព្រមពី "អ្នកម្ចាស់ការ" ផ្អែកលើមូលហេតុជាក់ស្តែង ។ "អ្នកទទួលការ" ត្រូវជូនដំណឹងពីរាល់ព្រឹត្តិការណ៍ដែលបណ្តាលឱ្យមានការយឺតយ៉ាវ ហើយ "អ្នកម្ចាស់ការ" ត្រូវពិនិត្យ និងសម្រេចលើការសុំពន្យារពេលបញ្ចប់ការងារមិនឱ្យលើសពីប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពីបានទទួលលិខិតស្នើសុំរបស់ "អ្នកទទួលការ" ។ ប្រសិនបើ "អ្នកទទួលការ" ខកខានក្នុងការប្រកាសជូនដំណឹងជាមុនអំពីការយឺតយ៉ាវ ឬខកខានក្នុងការធ្វើកិច្ចសហការ ដើម្បីដោះស្រាយការយឺតយ៉ាវនោះ ការយឺតយ៉ាវបែបនេះ មិនត្រូវបានពិចារណាដើម្បីផ្តល់ការពន្យារពេលបន្ថែមឡើយ។

(*ចំពោះកិច្ចលទ្ធកម្មដែលត្រូវពិនិត្យ និងសម្រេចដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការពន្យារពេលនោះ ត្រូវមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*) ។

**ប្រការ១០- ការសំអាតការដ្ឋាន**

"អ្នកទទួលការ" ត្រូវរក្សាភាពស្អាតជានិច្ចនៅការដ្ឋាន ហើយត្រូវប្រមូលចោលនូវសំរាម ឬរបស់របរផ្សេងៗ ដែលបានគរទុកពេលបញ្ចប់ "ការងារ" ។ "អ្នកទទួលការ" ត្រូវសំអាតការដ្ឋានឱ្យបានស្អាតល្អ មុននឹងប្រគល់ទៅឱ្យ "អ្នកម្ចាស់ការ" ។

**ប្រការ១១- ការបញ្ចប់ការងារ**

"ការងារ" ក្នុងកិច្ចសន្យាដែលត្រូវបានចាត់ទុកថាអនុវត្តចប់ គឺនៅពេលដែលការងារទាំងអស់ត្រូវបានបញ្ចប់ដោយត្រឹមត្រូវ និងឆ្លងកាត់ការត្រួតពិនិត្យចុងក្រោយពីគណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ ។ នៅពេលបញ្ចប់ "ការងារ" "អ្នកទទួលការ" ត្រូវស្នើសុំលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារពី "អ្នកម្ចាស់ការ" ។ "អ្នកម្ចាស់ការ" ត្រូវចេញលិខិតបញ្ជាក់ស្តីពីការបញ្ចប់ការងារ នៅក្នុងរយៈពេលដប់បួន(១៤)ថ្ងៃ បន្ទាប់ពីបានទទួលសំណើរបស់ "អ្នកទទួលការ" ដោយបញ្ជាក់អំពីកាលបរិច្ឆេទត្រឹមត្រូវ ឬអំពីការងារដែលនៅសល់ត្រូវបំពេញបញ្ចប់ ។

**ប្រការ១២- ការធានាគុណភាពសំណង់**

"អ្នកទទួលការ" ត្រូវធានាគុណភាពសំណង់ក្នុងរយៈពេល........ខែ(*សរសេរជាអក្សរ*..........) គិតចាប់ពីកាលបរិច្ឆេទនៃលិខិតបញ្ជាក់ពីការបញ្ចប់ "ការងារ" ។ ក្នុងរយៈពេលធានាគុណភាពសំណង់នេះ ប្រសិនបើពិនិត្យឃើញកន្លែងណាដែលមានលក្ខណៈមិនប្រក្រតី បណ្តាលមកពីខ្វះលក្ខណៈបច្ចេកទេស ដូចជា ជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ.......។ល។ នោះ "អ្នកម្ចាស់ការ" នឹងធ្វើលិខិតអញ្ជើញ "អ្នកទទួលការ" មកពិភាក្សាដើម្បីធ្វើការសាងសង់/ជួសជុលសំណង់ឡើងវិញ ។ ការចំណាយលើការសាងសង់/ជួសជុលខាង

*គំរូឯកសារដេញថ្លៃ ពិគ្រោះថ្លៃ ស្ទង់តម្លៃ (ដេញថ្លៃ សំណង់)* ទំព័រ

លើជាបន្ទុករបស់"អ្នកទទួលការ"ទាំងស្រុង ។ ប្រសិនបើក្នុងរយៈពេលប្រាំពីរ(០៧)ថ្ងៃ បន្ទាប់ពី "អ្នកម្ចាស់ការ" ធ្វើលិខិតស្នើទៅ "អ្នកទទួលការ" ឱ្យមកសាងសង់/ជួសជុលសំណង់ ហើយ"អ្នកទទួលការ"ពុំបានមកសាងសង់/ជួសជុលសំណង់ឡើងវិញនោះ "អ្នកម្ចាស់ការ" មានសិទ្ធិប្រគល់ការងារនេះឱ្យទៅអ្នកផ្សេងទៀតធ្វើជំនួស រីឯប្រាក់ទូទាត់ការងារនេះ "អ្នកម្ចាស់ការ" នឹងដកចេញពីប្រាក់កក់ធានាការអនុវត្តកិច្ចសន្យា ។ ករណីពិនិត្យឃើញថាមានការជ្រាបទឹក ប្រេះស្រាំ បែកបាក់ ការស្រុត ឬដួលរលំ...... បណ្តាលមកពីប្រធានស័ក្តិ នោះរាល់ការចំណាយលើការងារសាងសង់/ជួសជុលសំណង់ឡើងវិញជាបន្ទុករបស់ "អ្នកម្ចាស់ការ" ។

ការបញ្ចប់សុពលភាពធានាគុណភាពសំណង់ជាស្ថាពរ ត្រូវមានកំណត់ហេតុបញ្ជាក់ពីគណៈកម្មការប្រគល់ ទទួលសំណង់ច្បាស់លាស់ ដោយមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**ប្រការ១៣- ការបញ្ចប់កិច្ចសន្យា**

"អ្នកម្ចាស់ការ" អាចពិនិត្យពិចារណាបញ្ចប់កិច្ចសន្យាក្រោយរយៈពេលដប់ប្រាំ(១៥)ថ្ងៃ បន្ទាប់ពីបានជូនដំណឹងទៅឱ្យ "អ្នកទទួលការ" ដោយមូលហេតុដូចតទៅ ៖

- ការបន្តការងារទៅទៀត គឺមិនអាចធ្វើទៅបាន ឬបណ្តាលឱ្យខូចប្រយោជន៍ "អ្នកម្ចាស់ការ"
- "អ្នកទទួលការ" ស្ថិតក្នុងស្ថានភាពដែលមិនអាចសងបំណុលគេបាន ឬក៏គ្មានមធ្យោបាយហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីបញ្ចប់ការងារ
- "អ្នកទទួលការ" បានរំលោភលើលក្ខខណ្ឌមួយចំនួននៃកិច្ចសន្យា ហើយមិនអាចចាត់វិធានការកែតម្រូវលើកំហុសទាំងនោះ ។
- "អ្នកទទួលការ" មិនមានលទ្ធភាពធ្វើការសាងសង់/ជួសជុលតាមពេលវេលាដែលចែងក្នុងកិច្ចសន្យា
- "អ្នកទទួលការ" មិនអាចសងការខូចខាតនៅក្នុងលក្ខខណ្ឌណាមួយខាងលើក្នុងអំឡុងពេលដប់(១០)ថ្ងៃ បន្ទាប់ពីបានទទួលសេចក្តីជូនដំណឹងពីកំហុសដែលបានបញ្ជាក់ពីប្រភេទនៃកំហុស ។

**ប្រការ១៤- ការទូទាត់**

រូបិយប័ណ្ណសម្រាប់ធ្វើការទូទាត់គឺជាប្រាក់រៀល ។ ការទូទាត់តម្លៃកិច្ចសន្យា ត្រូវធ្វើតាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ...... ដោយបង្វែរចូលគណនីរបស់"អ្នកទទួលការ" លេខ............... នៅធនាគារ...................... ។ ការទូទាត់នឹងប្រព្រឹត្តទៅបានលុះត្រាតែភាគី "អ្នកទទួលការ" អនុវត្តជាក់ខាតបានត្រឹមត្រូវតាមគំនូសប្លង់ និងបទដ្ឋានបច្ចេកទេស ដែលបានចែងក្នុងកិច្ចសន្យា ដោយមានកំណត់ហេតុត្រួតពិនិត្យវាយតម្លៃច្បាស់លាស់របស់គណៈកម្មការវាយតម្លៃ និងប្រគល់ ទទួលសំណង់ (ព្រមទាំងមានការចូលរួមពីតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ) ។

ការទូទាត់ត្រូវធ្វើតាមដំណាក់កាលដូចខាងក្រោម ៖

**ដំណាក់កាលទី១** :  នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន.......% (.....*សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន.......% (.....*សរសេរជាអក្សរ*) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ ចំនួន............................. រៀល (*សរសេរជាអក្សរ*.......................) ។

**ដំណាក់កាលទី២** : នៅពេលដែល "អ្នកទទួលការ" អនុវត្ត "ការងារ" សម្រេចបាន.......% (.....*សរសេរជាអក្សរ*) នៃគម្រោងដែលមានចែងក្នុងកិច្ចសន្យានោះ "អ្នកម្ចាស់ការ" ត្រូវទូទាត់ជូន "អ្នកទទួលការ" នូវទឹកប្រាក់ចំនួន.......% (.....*សរសេរជាអក្សរ*) នៃតម្លៃកិច្ចសន្យាស្មើនឹងទឹកប្រាក់ ចំនួន.............................. រៀល (*សរសេរជាអក្សរ*.........................) ។

**ដំណាក់កាលទី**........ :

## ប្រការ១៥- ពន្ធ អាករ

"អ្នកទទួលការ" មានកាតព្វកិច្ចបង់ជូនរដ្ឋនូវពន្ធ អាករគ្រប់ប្រភេទ រួមទាំង "អាករលើតម្លៃបន្ថែម" តាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។ "អាករលើតម្លៃបន្ថែម" ត្រូវបង់តាម "វិធីកាត់ទុក" ដោយអគ្គនាយកដ្ឋានរតនាគារជាតិ ឬរតនាគារ........ នាពេលទូទាត់តម្លៃកិច្ចសន្យា ។

## ប្រការ១៦- ការផាកពិន័យ

ក្នុងករណីមានការយឺតយ៉ាវក្នុងការបញ្ចប់ "ការងារ" ដែលបណ្តាលមកពី "អ្នកទទួលការ" នោះ "អ្នកទទួលការ" ត្រូវទទួលរងនូវការផាកពិន័យចំនួន 0,១0% នៃតម្លៃកិច្ចសន្យាក្នុងមួយថ្ងៃ តាមចំនួនថ្ងៃដែលយឺតយ៉ាវ ។ ទោះបីយ៉ាងណាក៏ដោយចំនួនទឹកប្រាក់ផាកពិន័យនេះមិនត្រូវឱ្យលើសពី ១0% នៃតម្លៃកិច្ចសន្យា ។ ក្នុងករណីចំនួនទឹកប្រាក់ពិន័យនេះលើសពី ១0% នោះ "អ្នកម្ចាស់ការ" អាចពិចារណាបញ្ឈប់កិច្ចសន្យា ។

ក្នុងករណីដែលភាគី "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ/មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ..... រតនាគារ....... ) ធ្វើការទូទាត់យឺតយ៉ាវនោះ "អ្នកម្ចាស់ការ" និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវរងការពិន័យជាប្រាក់ជូន "អ្នកទទួលការ" ចំនួន 0,0៥% ក្នុងមួយថ្ងៃ លើចំនួនទឹកប្រាក់ដែលត្រូវទូទាត់ តាមចំនួនថ្ងៃដែលយឺតយ៉ាវនោះ ។

## ប្រការ ១៧- ការដោះស្រាយវិវាទ

កិច្ចសន្យានេះត្រូវគ្រប់គ្រង និងត្រូវបកស្រាយតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ជម្លោះណាមួយដែលកើតឡើងរវាងភាគី "អ្នកម្ចាស់ការ" និង ភាគី "អ្នកទទួលការ" អំពីលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា ឬទាក់ទិននឹងការអនុវត្តកិច្ចសន្យា ត្រូវដោះស្រាយតាមការសម្របសម្រួលជាមុនរវាងភាគីទាំងពីរ ។ ប្រសិនបើបរាជ័យនោះ ភាគីទាំងពីរត្រូវយល់ព្រមដោះស្រាយតាមរយៈមេធាវី ដោយភាគី "អ្នកម្ចាស់ការ" និងភាគី "អ្នកទទួលការ" មានសិទ្ធិជ្រើសតាំងមេធាវីម្នាក់មួយ ហើយអាជ្ញាកណ្តាលមួយរូបនឹងត្រូវតែងតាំងដោយមានការយល់ព្រមរវាងភាគីទាំងពីរ ។ ប្រសិនបើភាគីទាំងពីរមិនយល់ស្របគ្នាលើការតែងតាំង ឬមិនឯកភាពតាមការសម្រេចរបស់អាជ្ញាកណ្តាលនោះ ត្រូវដោះស្រាយតាមផ្លូវតុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ១៨- ការប្រើប្រាស់ឯកសារកិច្ចសន្យា

ប្រសិនបើគ្មានការយល់ព្រមពីភាគី" អ្នកម្ចាស់ការ" នោះ ភាគី"អ្នកទទួលការ" មិនត្រូវប្រើប្រាស់ឯកសារកិច្ចសន្យា ឬមិនត្រូវបង្ហាញ ឬផ្តល់ព័ត៌មានដែលមាននៅក្នុងឯកសារកិច្ចសន្យា ឱ្យទៅអ្នកដទៃដឹងទេ លើកលែងតែប្រើប្រាស់ក្នុងគោលបំណងអនុវត្តកាតព្វកិច្ចរបស់ខ្លួនតាមកិច្ចសន្យា ។

**ប្រការ១៩- ខ្សែសានវាន**

ភាគីទាំងពីរមានភារកិច្ចអនុវត្តតាមកិច្ចសន្យាឱ្យបានម៉ឺងម៉ាត់ ។ កិច្ចសន្យានេះត្រូវធ្វើជាភាសាខ្មែរចំនួន ប្រាំបួន (០៩) ច្បាប់ដើម មានតម្លៃដូចគ្នា និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ព្រមទាំងរក្សាទុកនៅ៖

| | |
|---|---|
| - ភាគី "អ្នកម្ចាស់ការ" | ចំនួន ០៣ ច្បាប់ |
| - ភាគី "អ្នកទទួលការ" | ចំនួន ០៣ ច្បាប់ |
| - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ) | ចំនួន ០១ ច្បាប់ |
| - មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ...... | ចំនួន ០១ ច្បាប់ |
| - ឯកសារ-កាលប្បវត្តិ | ចំនួន ០១ ច្បាប់ |

.................... ថ្ងៃទី ............... ខែ ............... ឆ្នាំ.............

**ភាគី "អ្នកម្ចាស់ការ"** **ភាគី "អ្នកទទួលការ"**

បានឃើញ និង ឯកភាព

............... ថ្ងៃទី .............. ខែ..........ឆ្នាំ .................

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

# តារាងឧបសម្ព័ន្ធភ្ជាប់កិច្ចសន្យា

## ស្តីពីការងារសាងសង់/ជួសជុល.....................................

| ល.រ | បរិយាយ | ឯកតា | បរិមាណ | តម្លៃឯកតា (ជារៀល) | តម្លៃសរុប (ជារៀល) | ផ្សេងៗ |
|---|---|---|---|---|---|---|
| I. | **ពលកម្ម** | | | | | |
| ១ | ការងាររុះរើរបងចាស់ | មៅ | 1 | ... | ... | |
| ២ | ការងារជីករណ្តៅ | ម៣ | 12.848 | ... | ... | |
| ៣ | ការងារចាក់ថ្នឹម | ម៣ | 9.250 | ... | ... | |
| ៤ | ការងាររៀបឥដ្ឋ | ម២ | 62.400 | ... | ... | |
| ៥ | ការងារបូកបាយអរ | ម២ | 254.150 | ... | ... | |
| ៦ | ការងារលាបស្តេគ្រូលរបងថ្មី | ម២ | 254.150 | ... | ... | |
| ៧ | ការងាររៀបបណ្តាញភ្លើង | ម | 51.390 | ... | ... | |
| ៨ | ការងារជីក្បាលសរសរ | ដើម | 14 | ... | ... | |
| ៩ | ការងារលាបស្តេគ្រូលរបងចាស់ | ម២ | 420 | ... | ... | |
| ១០ | ការងាររៀបគែមចិញ្ចើមស្មួន | ម | 61 | ... | ... | |
| ១១ | ការងាររៀបដើងទៀន | ដើម | 260 | ... | ... | |
| ... | .... | ... | ... | ... | ... | |
| | **សរុបចំណាយពលកម្ម** | | | | | |
| II. | **សម្ភារៈ** | | | | | |
| ១ | ស៊ីម៉ង់ត៍ | តោន | ... | ... | ... | |
| ២ | ដែកសរសៃគ្រប់ប្រភេទ | តោន | ... | ... | ... | |
| ៣ | លួសចំណង | គ.ក្រ | ... | ... | ... | |
| ៤ | ថ្ម ១ គុណ ២ | ម៣ | ... | ... | ... | |
| ៥ | ថ្ម ៤ គុណ ៦ | ម៣ | ... | ... | ... | |
| ៦ | ខ្សាច់រៀប បូក | ម៣ | ... | ... | ... | |
| ៧ | ក្តារពុម្ព និងរនូត | ម៣ | ... | ... | ... | |
| ៨ | កូនឈើធ្វើរន្ទា | ដើម | ... | ... | | |
| ៩ | ដែកគោល | សុង | ... | ... | | |
| ១០ | ឥដ្ឋប្រហោង | ដុំ | ... | ... | | |
| ១១ | ម្សៅបៀកជញ្ជាំងចំណុះ២៥គ.ក្រ/បាវ | បាវ | ... | ... | | |
| ១២ | ការស៊ីល័រ | ធុង | ... | ... | | |

| | | | | | | |
|---|---|---|---|---|---|---|
| ១៣ | ស្តេត្រូល | ធុង | ... | ... | ... | |
| ១៤ | ក្រដាសខាត់ | សន្លឹក | ... | ... | ... | |
| ១៥ | រូឡូរញស្តេត្រូល | ដើម | ... | ... | ... | |
| .... | ............. | ... | ... | ... | ... | |
| | **សរុបចំណាយសម្ភារៈ** | | | | ... | |
| III. | **ផ្សេងៗ** | | | | | |
| ១ | ដឹកជញ្ជូន | | | | ... | |
| ២ | សិក្សាគម្រោង | | | | ... | |
| | **សរុបចំណាយផ្សេងៗ** | | | | ... | |
| | **សរុបរួម** (I+II+III) | | | | ... | |

បញ្ឈប់ត្រឹមទឹកប្រាក់ : ................................................................................................រៀល

(សរសេរជាអក្សរ ...................................................................................................................)។

ធ្វើនៅ................ ថ្ងៃទី............ខែ.............ឆ្នាំ .............

**ភាគី "អ្នកម្ចាស់ការ"** **ភាគី "អ្នកទទួលការ"**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួង/ស្ថាប័ន/រាជធានី/ខេត្ត/ក្រុង/ស្រុក/ខណ្ឌ.....**

**គណៈកម្មាធិការលទ្ធកម្ម**

## កំណត់ហេតុប្រគល់ ទទួល

ការងារសាងសង់/ជួសជុល .........................................

**__យោង__** ៖ កិច្ចសន្យាលេខ ............/........ ចុះថ្ងៃទី .......ខែ.......... ឆ្នាំ ............. ស្តីពីការងារសាងសង់/ជួសជុល ............ រវាង...................ជាមួយក្រុមហ៊ុន/សហគ្រាស.......................។

ឆ្នាំ........... ខែ........... ថ្ងៃទី.......... វេលាម៉ោង.................. នៅ......................... មានបើកការប្រជុំក្រោមអធិបតីភាព.......................ដើម្បីពិនិត្យវាយតម្លៃនិងប្រគល់ ទទួលការងារសាងសង់/ជួសជុល ........... ។

**១-សមាសភាពចូលរួម**

ក- គណៈកម្មការប្រគល់ ទទួល

១- ................ មុខងារ..................

២-................ មុខងារ..................

៣-................ មុខងារ..................

...........................

ខ- "អ្នកម្ចាស់ការ"

ឈ្មោះ......... មុខងារ..................

គ- "អ្នកទទួលការ"

ឈ្មោះ......... មុខងារ..................

**២-មតិប្រធានអង្គប្រជុំ**.....................

**៣-របាយការណ៍របស់ "អ្នកម្ចាស់ការ"** (ក្រុមការងារត្រួតពិនិត្យបច្ចេកទេសជាមុន)..................

**៤-របាយការណ៍របស់ "អ្នកទទួលការ"** ..................

| ល.រ | បរិយាយ | ឯកតា | បរិមាណ | លទ្ធផលជាក់ស្តែង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ការងាររំាយរបងចាស់ | មៅ | 1 | 100% | |
| ២ | ការងារជីករណ្តៅ | ម៣ | 12.848 | 100% | |
| ៣ | ការងារចាក់ថ្នឹម | ម៣ | 9.250 | ........ | |

| | | | | | |
|---|---|---|---|---|---|
| ៤ | ការងាររៀបឥដ្ឋ | ម$^{២}$ | 62.400 | ........ | |
| ៥ | ការងារបូកបាយអរ | ម$^{២}$ | 254.150 | ........ | |
| ៦ | ការងារលាបស្ពៃគ្រូលរបងថ្មី | ម$^{២}$ | 254.150 | ........ | |
| ៧ | ការងាររៀបបណ្ដាញភ្លើង | ម | 51.390 | ........ | |
| ៨ | ការងារជ្រីក្បាលសរសរ | ដើម | 14 | ........ | |
| ៩ | ការងារលាបស្ពៃគ្រូលរបងចាស់ | ម$^{២}$ | 420 | ........ | |
| ១០ | ការងាររៀបគែមចិញ្ចើមស្មួន | ម | 61 | ........ | |
| ១១ | ការងាររៀបជើងទៀន | ដើម | 260 | ........ | |
| ... | .... | | | ........ | |
| | | | | | |

**៥-ការត្រួតពិនិត្យការដ្ឋានសំណង់ជាក់ស្តែង** ...............

| ល.រ | បរិយាយ | ឯកតា | បរិមាណ | លទ្ធផលជាក់ស្តែង | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | ការងារវាយរបងចាស់ | មៅ | 1 | 100% | |
| ២ | ការងារជីករណ្ដៅ | ម$^{៣}$ | 12.848 | 100% | |
| ៣ | ការងារចាក់ធ្នឹម | ម$^{៣}$ | 9.250 | ........ | |
| ៤ | ការងាររៀបឥដ្ឋ | ម$^{២}$ | 62.400 | ........ | |
| ៥ | ការងារបូកបាយអរ | ម$^{២}$ | 254.150 | ........ | |
| ៦ | ការងារលាបស្ពៃគ្រូលរបងថ្មី | ម$^{២}$ | 254.150 | ........ | |
| ៧ | ការងាររៀបបណ្ដាញភ្លើង | ម | 51.390 | ........ | |
| ៨ | ការងារជ្រីក្បាលសរសរ | ដើម | 14 | ........ | |
| ៩ | ការងារលាបស្ពៃគ្រូលរបងចាស់ | ម$^{២}$ | 420 | ........ | |
| ១០ | ការងាររៀបគែមចិញ្ចើមស្មួន | ម | 61 | ........ | |
| ១១ | ការងាររៀបជើងទៀន | ដើម | 260 | ........ | |
| ... | .... | | | ........ | |
| | | | | | |

**៦-មតិរបស់សមាជិកចូលរួម**...............

**៧-សេចក្តីសន្និដ្ឋានរបស់គណៈកម្មការប្រគល់ ទទួល ៖**

ក្រោយពីអង្គប្រជុំពិនិត្យ ពិភាក្សា និងវាយតម្លៃរួចមក គណៈកម្មការបានឯកភាពទទួលយកលទ្ធផលការងារដែលមានគុណភាព បរិមាណ និងលក្ខណៈបច្ចេកទេសត្រឹមត្រូវតាមកិច្ចសន្យា ។

ការត្រួតពិនិត្យ ប្រគល់ ទទួលបានចប់សព្វគ្រប់នៅថ្ងៃទី........ ខែ........ ឆ្នាំ.......... ។

................. ថ្ងៃទី............ខែ.............ឆ្នាំ............

**អ្នកធ្វើកំណត់ហេតុ**

**អ្នកម្ចាស់ការ**

................

**អ្នកទទួលការ**

.................

**គណៈកម្មការប្រគល់ ទទួល :**

១-............................

២-............................

៣-...........................

..............................

បានឃើញ និង ឯកភាព

................. ថ្ងៃទី............ខែ.............ឆ្នាំ .............

**ប្រធានអង្គប្រជុំ និងជា**

**ប្រធានគណៈកម្មាធិការលទ្ធកម្ម**

ត ទៅរាជកិច្ចលេខ ៣៧

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ១៤០ ឧស្ស.កវ.ប្រក.

# ប្រកាស
## ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ០៦៤/១៤ គ.វ.ក ចុះថ្ងៃទី០៩ ខែមករា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ស៊ីន ស្វ យីង អេនធើប្រាយ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០១៣

## សម្រេច

**ប្រការ១:** អនុញ្ញាតឲ្យក្រុមហ៊ុន ស៊ីន ស្វ យីង អេនធើប្រាយ (XIN SHUO YING ENTERPRISE CO., LTD.) តំណាងដោយ លោក GE, SAI សញ្ជាតិចិន អាយុ២១ឆ្នាំ កាន់លិខិតឆ្លងដែនលេខ E21187452 ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ មានអាសយដ្ឋានបច្ចុប្បន្ន Shang Hai Shi, Qing Pu Qu, Du Cun Gong Lu # 200 Hao ធ្វើការបង្កើតរោងចក្រ ដើម្បីផលិតផលដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១. ក្រដាស (ពណ៌ រូបភាព ក្រាហ្វិក....) | ១៧០១ |
| ២. ក្រដាសអនាម័យ | ១៧០៩ |
| ៣. សម្ភារៈវេចខ្ចប់ពីក្រដាស | ១៧០៩ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh Phone : 855-23-211141 Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រកាត់ក្រដាសទ្រនាប់ពុម្ពសម្លៀកបំពាក់ ស្បែកជើង កាបូប ក្រដាសម៉ាក់យី និងក្រដាសវេចខ្ចប់ ស៊ីន សូ យ៉ីង អេនធើប្រាយ"*

**ទីតាំងរោងចក្រ ៖** *"ដីឡូត៍លេខ២១៨ ភូមិត្រពាំងជ្រៃ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមប្បទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូត ដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ខែ មីនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**-សាលារាជធានីភ្នំពេញ**

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៤ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៤១ ឧស-កឧ-ប្រក

# ប្រកាស
# ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ ២៦៧/១៤ គ.វ.ក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន ភី.អាយ.ភី ខាថិន ហ្វេកធើរី ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន ភី.អាយ.ភី ខាថិន ហ្វេកធើរី (P.I.P CARTON FACTORY CO., LTD.) តំណាងដោយ លោកស្រី ហង់ ភីលី សញ្ជាតិខ្មែរ អាយុ៦៣ឆ្នាំ កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ 010005599 ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៦ មានអាសយដ្ឋានបច្ចុប្បន្ន៖ ផ្ទះលេខ១០ ផ្លូវលេខ៧១ ក្រុម៧១ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម ៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| កេសកាតុង | ១៧០២ |

**ផ្លាកឈ្មោះរោងចក្រ ៖** *"រោងចក្រផលិតកេះកាតុង ភី.អាយ.ភី ខាថិន ហ្វេកធើរី"*
**ទីតាំងរោងចក្រ ៖** *" ភូមិត្រពាំងជ្រៃ សង្កាត់កាកាប ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀតគ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់។

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណា ដែលគ្មានជំនាញ បច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាង និង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាប្បញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញ លក្ខខណ្ឌដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម **និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។**

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសប្បញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិសេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។

-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្ម រាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ក្រសួងបរិស្ថាន

-ក្រសួងពាណិជ្ជកម្ម

-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**-សាលារាជធានីភ្នំពេញ**

"ដើម្បីជូនជ្រាប"

-ដូចប្រការ១៥ "ដើម្បីអនុវត្ត"

-រាជកិច្ច

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៥៤ ឧស.គឧ.ប្រក.

# ប្រកាស
# ស្តីពីការបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងលិខិតលេខ១០១/១៤ត.វ.ក ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងពាក្យស្នើសុំរបស់ក្រុមហ៊ុន យីហាវ ក្រាហ្វ អេន ផែកឃិជីង (ខេមបូឌា) ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៣

## សម្រេច

**ប្រការ១៖** អនុញ្ញាតឲ្យក្រុមហ៊ុន យីហាវ ក្រាហ្វ អេន ផែកឃិជីង (ខេមបូឌា) (YIHAO CRAFTS AND PACKAGING (CAMBODIA) CO., LTD.) តំណាងដោយ លោក QIU DUOLONG សញ្ជាតិចិន អាយុ៥០ឆ្នាំ កាន់លិខិតឆ្លងដែនលេខG37325697 ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០០៩ មានអាសយដ្ឋានបច្ចុប្បន្ន៖ Room 1805, Parkland Villa, Tower 37B, Longgang, Shenzhen, China 518172. ធ្វើការបង្កើតរោងចក្រ លើមុខសញ្ញា ដូចខាងក្រោម៖

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ១- បន្ទះរូបភាព និងរូបផ្សេងៗពីជ័រសិប្បនិម្មិតទន់ | ២០១៣ |
| ២- សម្ភារៈវេចខ្ចប់(ពីក្រដាស) | ១៧០៩ |



៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ផ្លាកឈ្មោះរោងចក្រ៖** *"រោងចក្រផលិតវត្ថុអនុស្សាវរីយ៍ និងប្រដាប់វេចខ្ចប់ យីហោរ ក្រាហ្វ អេន កែកឃិជីង (ខេមបូឌា)"*

**ទីតាំងរោងចក្រ៖** *"អាគារលេខ៧៥ ៧៦ ៧៧ ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ"*

**ប្រការ២៖** -ម្ចាស់រោងចក្រ ត្រូវរៀបចំផែនការចាត់តាំងតម្លើង និងអនុវត្តឲ្យបានគ្រប់គ្រាន់នូវវិធានការចាំបាច់នានា ក្នុងការត្រួតពិនិត្យគុណភាពផលិតផល តាមមុខសញ្ញាផលិតកម្ម ដែលបានកំណត់ក្នុងប្រការ១ និងត្រូវអនុវត្តតាមបទប្បញ្ញត្តិបច្ចេកទេសទាំងឡាយ ដែលមានជាធរមាន។

-ម្ចាស់រោងចក្រ មិនត្រូវប្រើប្រាស់ទីតាំង និងមធ្យោបាយនានា របស់រោងចក្រនេះ ធ្វើការផលិត មុខផលិតផលណា ផ្សេងខុសពីមុខសញ្ញា ដែលបានកំណត់ក្នុងប្រការ១ ឡើយ។ ក្នុងករណីដែលម្ចាស់រោងចក្រ មានបំណងបង្កើតផលិតផលថ្មី បន្ថែមលើមុខសញ្ញាដែលបានកំណត់ក្នុងប្រការ១ ត្រូវធ្វើលិខិតជូនដំណឹង និងស្នើសុំចុះបញ្ជីមុខសញ្ញាផលិតកម្មថ្មី នៅអគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៣៖** -ម្ចាស់រោងចក្រត្រូវគោរពតាមច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ច្បាប់ផ្សេងៗទៀត និងរាល់អនុក្រឹត្យដែលពាក់ព័ន្ធជាមួយច្បាប់។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមសេចក្តីសម្រេច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងការដាក់វិធានការបទប្បញ្ញត្តិផ្សេងៗ និងត្រូវធ្វើសកម្មភាពដោយអនុលោមតាមអាណត្តិ និងលក្ខខណ្ឌ នៃប្រកាសនេះ។

-ម្ចាស់រោងចក្រ ត្រូវគោរពតាមកាតព្វកិច្ចការពារបរិស្ថាន ដែលបានកំណត់ក្នុងច្បាប់ ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ និង រាល់អនុក្រឹត្យនានា ស្តីពីការការពារបរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤៖** ម្ចាស់រោងចក្រ អាចគ្រប់គ្រងរោងចក្រដោយខ្លួនឯង ឬ ប្រគល់សិទ្ធិឲ្យអ្នកដទៃទៀត គ្រប់គ្រងរោងចក្រជំនួសខ្លួនបាន ដោយធ្វើការជូនដំណឹងជាលាយលក្ខអក្សរ មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ប៉ុន្តែ ក្នុងករណីណាក៏ដោយ ម្ចាស់រោងចក្រ ត្រូវតែទទួលខុសត្រូវ លើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួន ចំពោះ **មុខច្បាប់ និងអ្នកប្រើប្រាស់។**

**ប្រការ៥៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវធ្វើទៅតាមលក្ខណៈបច្ចេកទេស ដែលត្រូវបានកំណត់ដោយប្រកាសក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ជនណាដែលគ្មានជំនាញបច្ចេកទេស មិនអាចជួល ឬចាត់ឲ្យមករៀបចំរោងចក្រ បានឡើយ។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវលើកបង្ហាញផ្លាកឈ្មោះរោងចក្ររបស់ខ្លួន ជាអក្សរខ្មែរមានទំហំធំជាងនិង នៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលសាធារណជនងាយមើលឃើញ ពីមុខរោងចក្រ។

**ប្រការ៧៖** -មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រ ត្រូវជូនដំណឹងឲ្យបានមុនរយៈពេល ១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅអគ្គនាយកដ្ឋានឧស្សាហកម្ម។

-វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រនឹងត្រូវចេញឲ្យម្ចាស់រោងចក្រមានសុពលភាព ០៣ ឆ្នាំ តាមលក្ខខណ្ឌ ដូចខាងក្រោម ៖

ក.ម្ចាស់រោងចក្រ បានដាក់ពាក្យស្នើសុំត្រឹមត្រូវ

ខ.ម្ចាស់រោងចក្រ ផ្តល់ជូនក្រសួងពិនិត្យនូវរបាយការណ៍ និងផែនការផលិតកម្មប្រចាំឆ្នាំ តាមគំរូដែលបានកំណត់

គ.ម្ចាស់រោងចក្រ បង់ប្រាក់ទូទាត់រួចរាល់ នូវកាតព្វកិច្ចបង់កម្រៃសេវាបញ្ញត្តិកម្មរោងចក្រប្រចាំ ០៣ ឆ្នាំ។

**ប្រការ៨៖** -ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្រ របស់ខ្លួន។

-មុនផុតសុពលភាព ៣០ថ្ងៃ ម្ចាស់រោងចក្រ ត្រូវធ្វើការស្នើសុំពន្យារបន្តសុពលភាពថ្មីនៃវិញ្ញាបនបត្រអនុញ្ញាត ដំណើរការរោងចក្រ ដោយបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងប្រការ៧។

-ក្នុងរយៈពេល ៣០ថ្ងៃ ក្រោយថ្ងៃផុតសុពលភាព នៃវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ហើយម្ចាស់រោងចក្រ ពុំបានដាក់ពាក្យស្នើសុំពន្យារបន្តសុពលភាព ទេនោះ ក្រសួងនឹងធ្វើការដកហូតប្រកាសនេះវិញ ជាស្វ័យប្រវត្តិ។

**ប្រការ៩៖** -ម្ចាស់រោងចក្រ ត្រូវផ្តល់ឲ្យបានត្រឹមត្រូវនូវទិន្នន័យ និង របាយការណ៍ប្រចាំខែ ប្រចាំឆ្នាំ ជាបន្តបន្ទាប់ និងទៀងទាត់ តាមបែបបទ និងទំរង់កំណត់ ដូចមានភ្ជាប់ជាឧបសម្ព័ន្ធ ក្នុងប្រកាសនេះ។

-របាយការណ៍សង្ខេបប្រចាំខែ ត្រូវផ្តល់មកឲ្យ អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែបន្ទាប់ នៅរាល់ដំណាច់ខែ នីមួយៗ។

-របាយការណ៍ប្រចាំឆ្នាំ ត្រូវផ្តល់មក អគ្គនាយកដ្ឋានឧស្សាហកម្ម នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម នៅក្នុងអំឡុងពេលនៃសប្តាហ៍ទីមួយ នៃខែមករា នៃឆ្នាំបន្ទាប់។

-ករណីខកខាន ក្នុងការផ្តល់ទិន្នន័យព័ត៌មានតាមការកំណត់ ម្ចាស់រោងចក្រ នឹងត្រូវទទួលទោសបញ្ញត្តិ តាមមាត្រា៤៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** រាល់ផលិតផលជាទំនិញទាំងអស់ ដែលត្រូវចរាចរលើទីផ្សារ ត្រូវមានស្លាកសញ្ញាបញ្ជាក់សំគាល់ច្បាស់លាស់ អំពីអត្តសញ្ញាណនៃទំនិញ ប្រភេទផលិតកម្ម ស្របតាមបទប្បញ្ញត្តិ សេចក្តីណែនាំអំពីស្តង់ដារផលិតផល និងការចុះបញ្ជីផលិតផល។

**ប្រការ១១៖** លក្ខខណ្ឌនានា របស់ប្រកាសនេះអាចកែសម្រួល ឬធ្វើវិសោធនកម្មបាន អនុលោមតាមច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។ ប្រកាសនេះ អាចដកហូតស្របតាមមាត្រា ៣៩ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងតាមលក្ខខណ្ឌទាំងឡាយ នៃប្រកាសនេះ។

**ប្រការ១២៖** ក្នុងករណីរោងចក្រ ផ្អាកដំណើរការជាប់ៗគ្នាក្នុងរយៈពេល១២ខែ ឬប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងប្រការណាមួយ ដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតដោយគ្មានសំណងអ្វីឡើយ។

**ប្រការ១៣៖** -ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ច របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឲ្យមានប្រសិទ្ធភាពខ្ពស់។
-ម្ចាស់រោងចក្រ ត្រូវរាយការណ៍ជូនដំណឹង មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឲ្យបានឆាប់រហ័ស អំពីករណីប្រែប្រួលធំៗហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរ ដល់ដំណើរការប្រព្រឹត្តិទៅធម្មតា របស់រោងចក្រ។

**ប្រការ១៤៖** អគ្គនាយកឧស្សាហកម្ម ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ និងម្ចាស់រោងចក្រ ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្ត ប្រកាសនេះតាមមុខការរៀងៗខ្លួន។

**ប្រការ១៥៖** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិនា ឆ្នាំ២០១៤

**ជ.រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**រដ្ឋលេខាធិការ**

**សាត សាមី**

**ចម្លងជូន៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
-ក្រសួងបរិស្ថាន
-ក្រសួងពាណិជ្ជកម្ម
-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
-សាលារាជធានីភ្នំពេញ
"ដើម្បីជូនជ្រាប"
-ដូចប្រការ១៤ "ដើម្បីអនុវត្ត"
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ